ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ 003 សហវ.

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែមករា ឆ្នាំ២០១៤

# សារាចរណែនាំ
# ស្តីពី
# ការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤

## I. សេចក្តីផ្តើម

**១**- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១១១៣/០១៥ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៣។ ដើម្បីអនុវត្តច្បាប់នេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ៥៦៤ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណូលថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងអនុក្រឹត្យលេខ៥៦៥ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ផ្អែកលើមូលដ្ឋាននៃច្បាប់ និងអនុក្រឹត្យនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសលេខ ១៥២០ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការប្រគល់ភារកិច្ចប្រមូលចំណូលថវិកាថ្នាក់ជាតិសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ និងប្រកាសលេខ១៥២១ សហវ.ប្រក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិផ្ទៃក្នុងជំពូក តាមគណនី និងអនុគណនី សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**២**- ថវិកាឆ្នាំ២០១៤ គឺជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុតសម្រាប់រាជរដ្ឋាភិបាល ដោះស្រាយបាននូវសេចក្តីត្រូវការរបស់ប្រជាជន ដែលបានស្តែងឡើងតាមរយៈលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ និងឆ្លើយតបទៅនឹងគោលនយោបាយជាអាទិភាព ដែលមានចែងក្នុងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា ជាពិសេស ថវិកាឆ្នាំ២០១៤ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹង **"គោលដៅជាយុទ្ធសាស្ត្រ ៤"** គឺ កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដោយផ្តល់ការយកចិត្តទុកដាក់លើ **"វិស័យអាទិភាព ៤"** នៃ**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** គឺ ៖

ទី១- ការអភិវឌ្ឍធនធានមនុស្សនិងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតជាពិសេសលើយុវជន។

ទី២- ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីបង្កើនភាពទាក់ទាញនិងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា។

ទី៣-ការបន្តអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈការបង្កើនផលិតភាព ទំនើបកម្មកសិកម្ម ឧស្សាហូបនីយកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម។

ទី៤-ការពង្រឹងអភិបាលកិច្ចនិងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាពនិងគុណភាពសេវាសាធារណៈ និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការវិនិយោគនិងធុរកិច្ច ពិសេសការកែលម្អបរិស្ថានវិនិយោគ តាមរយៈការកាត់បន្ថយថ្លៃដើមនិងរបាំងធុរកិច្ច។

នៅក្នុងការឆ្លើយតបទៅនឹងអាទិភាពជាយុទ្ធសាស្ត្រទាំង ៤ នេះ ការផ្តោតការយកចិត្តទុកដាក់ពិសេសទៅលើការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គឺជាចំណុចលេចធ្លោជាងគេនៃថវិកាឆ្នាំ ២០១៤។

**៣**- ថវិកាឆ្នាំ ២០១៤ ត្រូវបានរៀបចំឡើងដោយផ្អែកលើសូចនាករម៉ាក្រូសេដ្ឋកិច្ចសំខាន់ៗ ដូចខាងក្រោម ៖

- កំណើនសេដ្ឋកិច្ចតាមថ្លៃថេរនឹងសម្រេចបានក្នុងរង្វង់ ៧% ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នមានចំនួន ៦៨ ៦១៩ ០០០លានរៀល ដែលត្រូវជាប្រមាណ ១៦ ៩៤៣លានដុល្លារអាមេរិក។ ដូច្នេះនៅឆ្នាំ២០១៤ ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់អាចនឹងឡើងដល់ ១ ១៣៩ ដុល្លារអាមេរិក ហើយធ្វើឱ្យកម្ពុជាអាចនឹងចេញផុតពីចំណាត់ថ្នាក់ជាប្រទេសមានចំណូលទាប (Low Income Status-LIS) ក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប (Lower Middle-Income Status-LMIS) ក្នុងពេលឆាប់ៗខាងមុខ។
- អតិផរណានឹងត្រូវបានរក្សាឱ្យស្ថិតក្នុងរង្វង់ ៣,៥% ដោយរាជរដ្ឋាភិបាលបន្តអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈនិងគោលនយោបាយរូបិយវត្ថុសមស្របនិងប្រុងប្រយ័ត្ន។
- អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិកនឹងត្រូវបានរក្សាឱ្យស្ថិតក្នុងរង្វង់ ៤ ០៥០រៀល ក្នុង ១ដុល្លារអាមេរិក។
- ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្រៅប្រទេស នឹងត្រូវកាត់បន្ថយពី -៩,៥% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ មកត្រឹម-៩,៣% នៃផ.ស.ស. ក្នុងឆ្នាំ២០១៤ ដោយសារការកើនឡើងនៃការនាំចេញ ជាពិសេសកំណើននៃការនាំចេញទំនិញពីវិស័យកសិកម្មនិងវិស័យអេឡិចត្រូនិច។ ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់នៅមានកម្រិតខ្ពស់ ហើយកម្ពុជាត្រូវបន្តខិតខំកាត់បន្ថយឱ្យនៅកម្រិតសមស្របក្នុងរយៈពេលមធ្យមខាងមុខ។

**៤**- ដើម្បីសម្រេចបានតាមគោលដៅនៃអាទិភាពគោលនយោបាយ និងគោលដៅខាងម៉ាក្រូសេដ្ឋកិច្ចដូចបានគូសបញ្ជាក់ខាងលើ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ បានកំណត់ក្របខណ្ឌថវិកាឆ្នាំ២០១៤ ដូចតទៅ៖

-ចំណាយសរុបនៃថវិការដ្ឋស្មើនឹង ២០,៦៥% នៃផ.ស.ស.

-ចំណូលក្នុងប្រទេសសរុបនៃថវិការដ្ឋត្រូវសម្រេចឱ្យបានស្មើនឹង ១៥,៣៣% នៃផ.ស.ស.

-អតិរេកចរន្តត្រូវរក្សាឱ្យបានក្នុងកម្រិតប្រមាណ ២,២៨% នៃផ.ស.ស.

-ឱនភាពថវិកាសរុបត្រូវបានកាត់បន្ថយឱ្យនៅត្រឹមកម្រិតប្រមាណ -៥,៣២% នៃផ.ស.ស.

ជាមួយគ្នានេះ ដើម្បីសម្រេចបានក្របខ័ណ្ឌថវិកានេះ រាជរដ្ឋាភិបាលបានដាក់ចេញគោលនយោបាយថវិកា រួមមានដូចខាងក្រោម៖

១)-បន្តខិតខំបង្កើនចំណូលឱ្យបានធំជាង ១% នៃផ.ស.ស. ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ដើម្បីដោះស្រាយសេចក្តីត្រូវការចំណាយទៅតាមវិស័យអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល។

២)-បង្កើនអតិរេកចរន្តនៃថវិកា ដើម្បីបង្កើនសមត្ថភាពវិនិយោគពីប្រភពថវិកាផ្ទាល់របស់រាជរដ្ឋាភិបាលលើវិស័យអាទិភាព ពិសេសសំដៅលើកស្ទួយផលិតភាព និងកំណើនសេដ្ឋកិច្ច និងគ្រប់គ្រងសេវាបំណុលប្រកបដោយចិរភាព។

៣)-ទន្ទឹមនឹងនេះ បន្តខិតខំកាត់បន្ថយឱនភាពទូទៅនៃថវិកាឱ្យមកស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងរយៈពេលវែងខាងមុខ ពិសេសតាមរយៈការអនុវត្តដោយហ្មត់ចត់នូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលរបស់រាជរដ្ឋាភិបាល រួមមានគោលការណ៍បួនចំណុចគឺ ៖

ទី១- ខ្ចីក្នុងទំហំសមស្រប ដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន

ទី២- ខ្ចីតែឥណទានសម្បទាន

ទី៣- ខ្ចីសម្រាប់វិស័យទ្រទ្រង់កំណើន និង បង្កើនផលិតភាព

ទី៤- ប្រើប្រាស់កម្ចីទាំងនោះឱ្យមានតម្លាភាព និងប្រសិទ្ធភាពខ្ពស់បំផុត

៤)-រៀបចំឱ្យមានតុល្យភាពជាអតិរេកសាច់ប្រាក់ខ្លះ (ប្រមាណ ៧០ពាន់លានរៀល) សម្រាប់ពង្រឹងភាពធន់នៃសេដ្ឋកិច្ច។

ដូច្នេះ ដើម្បីឱ្យការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ សម្រេចបានតាមគោលដៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមធ្វើការណែនាំលើការអនុវត្តថវិកាថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៤ ដូចខាងក្រោម៖

## II. លក្ខខណ្ឌ និងវិធានការក្នុងការអនុវត្តចំណូល-ចំណាយថវិកាឆ្នាំ២០១៤

### ក- ការអនុវត្តការប្រមូលចំណូលថវិកា

**៥-** ក្នុងក្របខ័ណ្ឌនៃគោលដៅខាងលើ និងក្នុងគោលបំណងធានាឱ្យមានលំហថវិកាឆ្នាំ២០១៤ ជាពិសេសមានសាច់ប្រាក់ត្រៀមបម្រុងសម្រាប់ឆ្នាំទី១នៃការអនុវត្ត **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣"** រាជរដ្ឋាភិបាលត្រូវបង្កើនចំណូលក្នុងប្រទេសថ្នាក់ជាតិឱ្យស្មើនឹង ១៤,៤៥% នៃផ.ស.ស. គឺស្មើនឹង ៩ ៩៤៥ ៦២៧ លានរៀល ដែលមានកំណើន ១៦,២% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៣ និង ១៩,៣% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣។ តាមគោលដៅនេះ៖

ចំណូលចរន្ត ត្រូវសម្រេចឱ្យបានចំនួន ៩ ៧១២ ៦២៧ លានរៀល គឺមានកំណើន ១៤,៦% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៧,៦% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ១៤,១៥% នៃ ផ.ស.ស. ដែលក្នុងនោះ៖

- ចំណូលសារពើពន្ធ ត្រូវសម្រេចឱ្យបានចំនួន ៨ ៣០៨ ៦២១,២ លានរៀល គឺមានកំណើន ១៣,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៧,៤% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៣ ត្រូវជា១២,១១% នៃផ.ស.ស. ដែលក្នុងនោះ៖
  - ចំណូលគយ និងរដ្ឋាករ ត្រូវសម្រេចឱ្យបានចំនួន ៤ ៦៣៣ ៥០០ លានរៀល គឺមានកំណើន ១៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៩,៩% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ៦,៧៥% នៃផ.ស.ស.។
  - ចំណូលពន្ធដារ ត្រូវសម្រេចឱ្យបានចំនួន ៣ ៤២៩ ៨០០ លានរៀល គឺមានកំណើន ១២,៤% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៤,៦% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ៥% នៃ ផ.ស.ស.។
  - ចំណូលសារពើពន្ធផ្សេងៗ ត្រូវសម្រេចឱ្យបានចំនួន ២៤៥ ៣២១,២ លានរៀល គឺមានកំណើន ២០,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១១,៨% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ០,៣៦% នៃ ផ.ស.ស.។
- ចំណូលមិនមែនសារពើពន្ធ ត្រូវសម្រេចឱ្យបានចំនួន ១ ៤០៤ ០០៥,៨ លានរៀល គឺមានកំណើន ២១,៨% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៩,២% ធៀបនឹងការប៉ាន់ ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ២,០៥% នៃផ.ស.ស.។

ចំណូលមូលធន ត្រូវសម្រេចឱ្យបានចំនួន ៣ ៩៥៣ ០០០លានរៀល គឺមានកំណើន ១៤,៦% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៤% ធៀបនឹងការប៉ាន់ស្មានអនុវត្ត ឆ្នាំ២០១៣ ត្រូវជា ៥,៧៦% នៃ ផ.ស.ស. ដែលក្នុងនោះ ៖

- ចំណូលមូលធនក្នុងប្រទេស ត្រូវសម្រេចឱ្យបានចំនួន ២៣៣ ០០០លានរៀល គឺមានកំណើន ១៨៤,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ១៩៤,៩% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ០,៣៤% នៃផ.ស.ស.។
- ចំណូលមូលធនក្រៅប្រទេស ត្រូវសម្រេចឱ្យបានចំនួន ៣ ៧២០ ០០០លានរៀល គឺមានកំណើន១០,៥% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ៩,៨% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ៥,៤២% នៃផ.ស.ស. ដែលក្នុងនោះ៖
  - ចំណូលពីហិរញ្ញប្បទានក្រៅប្រទេសសម្រាប់ទ្រទ្រង់ថវិកា ត្រូវបានគ្រោងចំនួន ២៦០ ០០០ លានរៀល គឺមានកំណើន ១៧,១% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និង ៦,៨% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ០,៣៨% នៃផ.ស.ស.។
  - ចំណូលពីហិរញ្ញប្បទានក្រៅប្រទេសសម្រាប់គម្រោងវិនិយោគ ត្រូវបានគ្រោងចំនួន ៣ ៤៦០ ០០០ លានរៀល គឺមានកំណើន ១០% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ២០១៣ និងការប៉ាន់ស្មានអនុវត្តឆ្នាំ ២០១៣ ត្រូវជា ៥,០៤% នៃផ.ស.ស.។

៦- ដើម្បីសម្រេចបានតាមគោលដៅខាងលើ អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រូវរៀបចំអនុវត្តនិងតាមដានជាប្រចាំនូវកម្មវិធីប្រមូលចំណូលសារពើពន្ធប្រចាំត្រីមាសដែលមានការបែងចែកលម្អិតទៅតាមខែ។ បើគិតជាមធ្យមភាគប្រចាំខែ អគ្គនាយកដ្ឋានពន្ធដារមានភារកិច្ចប្រមូលចំណូលពន្ធ ដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យមចំនួនប្រមាណ ២៨៥ ៨១៧លានរៀលក្នុងមួយខែ។ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាមានភារកិច្ចប្រមូលចំណូលពន្ធនិងអាករដែលជាចំណូលថវិកាថ្នាក់ជាតិឱ្យបានជាមធ្យមចំនួនប្រមាណ ៣៨៦ ១២៥ លានរៀលក្នុងមួយខែ។ ដោយឡែកចំពោះចំណូលសារពើពន្ធផ្សេងៗទៀតទាំងថ្នាក់ជាតិនិងរាជធានីខេត្ត ត្រូវប្រមូលឱ្យបានជាមធ្យមចំនួនប្រមាណ ៦៥ ៧៦៥លានរៀលក្នុងមួយខែ។ ទន្ទឹមនឹងនេះ កម្មវិធីប្រមូលចំណូលនេះ ត្រូវមានផែនការសកម្មភាពអនុវត្តលម្អិត និងទៅតាមប្រភេទនិងមាតិកាចំណូលនីមួយៗ ហើយប្រគល់ឱ្យតាមសាខាទីស្នាក់ការ ឬ/និងមន្ត្រីដែលមានភារកិច្ច និងការទទួលខុសត្រូវដោយផ្ទាល់ក្នុងការអនុវត្ត។

៧- ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរបស់ខ្លួននៅតាមរាជធានី-ខេត្ត ត្រូវរៀបចំកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស ដែលមានការបែងចែកលម្អិតតាមខែ ដោយផ្អែកលើកិច្ចសន្យានៃការជួលទ្រព្យសម្បត្តិរដ្ឋ កិច្ចសន្យាសម្បទាននានា ចំណូលពីសេវាបង់ថ្លៃ សកម្មភាពអាជីវកម្ម និងសង្វាក់នៃការប្រមូលចំណូលកន្លងមក ព្រមទាំងដាក់ចេញនូវផែនការសកម្មភាព និងវិធានការអនុវត្តលម្អិត និងទៅតាមប្រភេទ និងមាតិកាចំណូលនីមួយៗ។ អង្គភាពប្រមូលចំណូលត្រូវធ្វើការតាមដាន និងជំរុញជាប្រចាំ នូវការអនុវត្តកម្មវិធីប្រមូលចំណូលមិនមែនសារពើពន្ធប្រចាំត្រីមាស និងរិះរកវិធានការទាន់ពេលវេលាក្នុងករណីពិនិត្យឃើញថា ការប្រមូលចំណូលសម្រេចបានលទ្ធផលទាបជាងកម្មវិធីកំណត់។

៨- ដើម្បីសម្រេចបានតាមគោលដៅនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤ ដូចបានគូសបញ្ជាក់ខាងលើ ក៏ដូចជាដើម្បីបង្កើនប្រសិទ្ធភាពនៃការកៀរគរចំណូលបណ្តាឆ្នាំខាងមុខ រាជរដ្ឋាភិបាលនឹងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងសិក្សារៀបចំច្បាប់ស្តីពីអាករពិសេស ព្រមទាំងបន្តជំរុញការអនុវត្តគោលនយោបាយ/យុទ្ធសាស្ត្រ/ផែនការសកម្មភាព រាល់ក្របខ័ណ្ឌច្បាប់ បទបញ្ជា និងវិធានការទាំងឡាយដែលមានស្រាប់ ព្រមទាំងបង្កើនការអប្បមាទជាប្រចាំ ដើម្បីដាក់ចេញនូវគោលនយោបាយ និងវិធានការជាក់ស្តែងឱ្យទាន់ពេលវេលាបន្ថែមទៀត ដែលមានលក្ខណៈជាប្រព័ន្ធប្រកបដោយភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាព ពិសេសផ្តោតការយកចិត្តទុកដាក់លើការងារអាទិភាពមួយចំនួនដូចខាងក្រោម៖

## ទី១-<u>អគ្គនាយកដ្ឋានពន្ធដារ</u>

៩- វិធានការគោលនយោបាយសំខាន់ៗមានដូចខាងក្រោមៈ

- បន្តពង្រឹងការគ្រប់គ្រង និងជំរុញការប្រមូលចំណូលពន្ធ ជាពិសេសការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- បន្តពង្រឹងការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយ និងឱ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ។

- រៀបចំ និងកែលម្អលិខិតបទដ្ឋានស្តីពីពន្ធក្នុងវិស័យរ៉ែ ប្រេងកាតនិងឧស្ម័ន ដើម្បីធានាឱ្យបាននូវការប្រមូលចំណូលប្រកបដោយប្រសិទ្ធភាព ដោយធ្វើវិសោធនកម្មលើច្បាប់ស្តីពីសារពើពន្ធ ដើម្បីរៀបចំបញ្ចូលពន្ធលើរ៉ែ ប្រេងកាតនិងឧស្ម័ន។

- ពិនិត្យអំពីលទ្ធភាពធ្វើវិសោធនកម្មអនុក្រឹត្យ និងប្រកាសអាករពិសេសលើបារី ស្រា និងស្រាបៀរ ដោយដំឡើងអត្រា និងមូលដ្ឋានគិតអាករពិសេស។ ពង្រឹងការគ្រប់គ្រងប្រមូលអាករពិសេសលើទំនិញក្នុងស្រុកទាំងអស់ឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ តាមរយៈការដាក់មន្ត្រីប្រចាំការនៅតាមរោងចក្រផលិតផលិតផលជាប់អាករពិសេសក្នុងស្រុក និងការរៀបចំយន្តការបិទសន្លឹកតែមប្រើដែលមានសុវត្ថិភាព និងសន្តិសុខជាងមុនលើទំនិញទាំងនោះមុននឹងដាក់ឱ្យធ្វើចរាចរនៅលើទីផ្សារ។

- វិសោធនកម្មអនុក្រឹត្យស្តីពីអាករលើតម្លៃបន្ថែម ដោយបន្ថយកម្រិតផលរបរចុះបញ្ជីក្នុងរបបស្វ័យប្រកាស ដើម្បីពង្រីកមូលដ្ឋានជាប់ពន្ធក្នុងរបបស្វ័យប្រកាស។

- រៀបចំគំរូសន្ធិសញ្ញាពន្ធ និងធ្វើការចរចាជាមួយប្រទេសដទៃទៀត ដើម្បីទាក់ទាញវិនិយោគទុនបរទេស ទប់ស្កាត់អំពើជៀសវាងពន្ធ (Tax Avoidance) ការគេចវេះពន្ធ (Tax Evasion) និងជៀសវាងការយកពន្ធត្រួតគ្នា។

- ពិនិត្យឡើងវិញនូវរបបលើកទឹកចិត្តផ្នែកពន្ធដារ ចំពោះគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីបង្កើនចំណូល បន្ថយការគេចវេះពន្ធ និងធ្វើឱ្យមានសមធម៌ក្នុងការប្រកួតប្រជែង។

- រៀបចំប្រកាស សេចក្តីជូនដំណឹង សារាចរណែនាំផ្សេងៗ លើប្រភេទពន្ធមួយចំនួន ដើម្បីឱ្យមានតម្លាភាពងាយស្រួលក្នុងការអនុវត្តតាមបទប្បញ្ញត្តិ និងច្បាប់ស្តីពីសារពើពន្ធ។

**១០**- វិធានការរដ្ឋបាលសំខាន់ៗមានដូចខាងក្រោមៈ

- ពង្រឹងការគ្រប់គ្រងប្រមូលពន្ធនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ទាំងរបបស្វ័យប្រកាសនិងរបបម៉ៅការ ជាពិសេសពង្រឹងការកំណត់ផលរបររបស់អ្នកជាប់ពន្ធឱ្យស្របតាមការប្រកបអាជីវកម្មជាក់ស្តែង ក្នុងទិសដៅបង្កើនចំនួនអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស បន្ថយចំនួនអ្នកជាប់ពន្ធតាមរបបម៉ៅការ និងពិនិត្យស្រាវជ្រាវសហគ្រាសដែលមិនទាន់មកបង់ពន្ធឱ្យមកបំពេញកាតព្វកិច្ចសារពើពន្ធ។

- ពង្រឹងការផ្តល់សេវាដល់អ្នកជាប់ពន្ធ ដោយរៀបចំសិក្ខាសាលាផ្សព្វផ្សាយណែនាំច្បាប់និងបទប្បញ្ញត្តិនានាស្តីពីពន្ធដារ ឆ្លើយតបជាលាយលក្ខណ៍អក្សរ និងតាមទូរស័ព្ទនូវចម្ងល់ ឬសំណួររបស់អ្នកជាប់ពន្ធ និងបោះពុម្ពជាកូនសៀវភៅ ឬប័ណ្ណពន្យល់ណែនាំដល់អ្នកជាប់ពន្ធ។ បិទផ្សាយនូវតម្លៃសេវាសាធារណៈ រៀបចំប័ណ្ណផ្ទាំងផ្សព្វផ្សាយ និងបិទនៅតាមកន្លែងបំពេញការងារ បង្កើតប្រអប់សំបុត្រ និងអ៊ីម៉ែលទទួលពាក្យបណ្តឹង និងបង្កើតមជ្ឈមណ្ឌលពិគ្រោះយោបល់តាមទូរស័ព្ទ (Call Center) និងការិយាល័យទំនាក់ទំនងសាធារណៈ (Public Relation Office)។

- ធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យាដើម្បីបម្រើឱ្យការប្រមូលចំណូលពន្ធ ការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម ការប្រមូលបំណុល និងការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ ដូចជាៈ រៀបចំនិងកែលម្អប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) ប្រព័ន្ធផ្តល់ព័ត៌មាន (Notification System) ជូនអ្នកជាប់ពន្ធ បង្កលក្ខណៈងាយស្រួលដល់អ្នកជាប់ពន្ធអាចបង់ប្រាក់តាមប្រព័ន្ធធនាគារ ឬតាមអេឡិចត្រូនិច (E-Tax)។

- ពង្រឹងការធ្វើសវនកម្មឱ្យមានប្រសិទ្ធភាព ដោយកែលម្អយន្តការកំណត់ហានិភ័យ ការជ្រើសរើសអ្នកជាប់ពន្ធ ដើម្បីធ្វើសវនកម្មព្រមទាំងបង្កើតការិយាល័យស៊ើបអង្កេតបទល្មើសសារពើពន្ធ។

- ពង្រឹងការប្រមូលព័ត៌មាន ដោយសហការជាមួយអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ក្រសួងពាណិជ្ជកម្ម ធនាគារ អគ្គិសនីកម្ពុជា និងស្ថាប័នពាក់ព័ន្ធនានា។

- អនុវត្តវិធានការតឹងទារបំណុលពន្ធចំពោះអ្នកជំពាក់បំណុលពន្ធ តាមរយៈការឃាត់ទុកគណនីនៅធនាគារ ការបញ្ឈប់ការនាំចេញនាំចូលទំនិញដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ការទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាប័ណ្ណ ការមិនអនុញ្ញាតឱ្យនាំចូលវត្ថុធាតុដើមដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ការកាត់ទុកប្រាក់ពន្ធនៅអគ្គនាយកដ្ឋានរតនាគារជាតិ ការមិនអនុញ្ញាតឱ្យចូលដេញថ្លៃ ការមិនអនុញ្ញាតឱ្យផ្ទេរកម្មសិទ្ធិអចលនទ្រព្យឬផ្ទេរភាគហ៊ុន ការមិនអនុញ្ញាតឱ្យចុះបញ្ជីបង្កើតក្រុមហ៊ុនថ្មី ការចុះផ្សាយឈ្មោះអ្នកជំពាក់បំណុលក្នុងសារព័ត៌មាន ការសហការជាមួយនគរបាលជាតិ និងប្តឹងទៅតុលាការដែលជាជម្រើសចុងក្រោយ។

- បន្តបណ្តុះបណ្តាលដើម្បីពង្រឹងសមត្ថភាពវិជ្ជាជីវៈ និងជ្រើសរើសមន្ត្រីថ្មីឆ្លើយតបនឹងតម្រូវការ។

**១១**- វិធានការអភិបាលកិច្ចសំខាន់ៗមានដូចខាងក្រោមៈ

- ពង្រឹងការងារអភិបាលកិច្ចល្អរបស់អគ្គនាយកដ្ឋានពន្ធដារ តាមរយៈការពង្រឹងការអនុវត្តក្រមសីលធម៌និងផ្លាស់ប្តូរផ្នត់គំនិតមន្ត្រីពន្ធដារឱ្យទៅជាអ្នកផ្តល់សេវាកាន់តែល្អប្រសើរជូនអ្នកជាប់ពន្ធ។

- កែសម្រួលប្រព័ន្ធលើកទឹកចិត្តមន្ត្រីពន្ធដារ និងអនុវត្តវិធានការដាក់ទោសទណ្ឌចំពោះមន្ត្រីដែលប្រព្រឹត្តខុស។

## ទី២-<u>អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា</u>

**១២**- វិធានការគោលនយោបាយសំខាន់ៗមានដូចខាងក្រោមៈ

- ការគ្រប់គ្រងចំណូលដែលបាត់បង់ពីការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា៖ រួមមាន (១)ការបន្តពិនិត្យលទ្ធភាពកែសម្រួលអត្រាអាករពិសេស និង(២)ការពិនិត្យលទ្ធភាពកាត់បន្ថយឬព្យួរការដាក់ពន្ធនិងអាករជាបន្ទុករបស់រដ្ឋលើមុខសញ្ញាមួយចំនួន។

- ការគ្រប់គ្រងឱ្យបានហ្មត់ចត់របបពន្ធឬអាករជាបន្ទុករបស់រដ្ឋ៖ រួមមាន (១)ការត្រួតពិនិត្យយ៉ាងហ្មត់ចត់រាល់សំណើសុំនាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋរបស់បុគ្គលនានាដែលមិនមែនជាវិនិយោគគិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និង(២)ធ្វើវិចារណកម្មគោលនយោបាយលើកលែងពន្ធចំពោះវិស័យមិនមែនកាត់ដេរនិងបុគ្គលផ្សេងទៀត។

- ការបន្តអភិវឌ្ឍវិស័យរដ្ឋាករតាមការអនុវត្តល្អជាអន្តរជាតិ៖ រួមមាន (១)បន្តជំរុញកសាងបទប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យរដ្ឋាករតាមការអនុវត្តល្អក្នុងតំបន់ (២)ពិនិត្យលទ្ធភាពកែសម្រួលអត្រាអាករពិសេសលើមុខទំនិញមួយចំនួន និងធ្វើបច្ចុប្បន្នភាពមុខទំនិញដែលអាចជាប់អាករពិសេស និង(៣)ពិនិត្យឡើងវិញនូវនីតិវិធីដែលមានស្រាប់ពាក់ព័ន្ធនឹងការលើកទឹកចិត្តអាករពិសេស និងយន្តការឃ្លាំមើលអនុលោមភាព។

- ការវាយតម្លៃផលប៉ះពាល់ពីផលិតកម្មក្នុងស្រុកជំនួសការនាំចូល៖ រួមមាន (១)ការពិនិត្យឡើងវិញនូវបញ្ជីទំនិញនាំចូលដែលមានវេទយិតភាពចំណូលខ្ពស់ និងត្រូវបានផលិតជំនួសវិញនៅក្នុងប្រទេស (២)ពិនិត្យជាអាទិភាពនូវផលប៉ះពាល់ចំណូលពន្ធអាករគយ និងលទ្ធភាពនៃការដាក់ឬដំឡើងអត្រាអាករពិសេសលើទំនិញទាំងនេះ និង(៣)ពិនិត្យលទ្ធភាពចូលរួមគ្រប់គ្រងតាមបទប្បញ្ញត្តិជាធរមាននូវផលិតកម្មដ្ឋានក្នុងស្រុកមួយចំនួន។

**១៣**- វិធានការរដ្ឋបាលសំខាន់ៗមានដូចខាងក្រោម៖

- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយតាមការិយាល័យត្រួតពិនិត្យបែបបទគយនាមាត់ច្រកព្រំដែនក៏ដូចជានៅក្នុងប្រទេស៖ នេះជាយន្តការដើមទី រួមមាន (១)ការពង្រឹងសង្គតិភាពនៃឯកសារនាំចេញនាំចូល (២)ការពង្រឹងអនុលោមភាពក្នុងការគិតពន្ធគយ ការប្រមូលនិងការបង់ចំណូលគយនិងរដ្ឋាករ (៣)ការឃ្លាំមើលអនុលោមភាពនៃនីតិវិធីគយរបស់ថ្នាក់ដឹកនាំគយគ្រប់ជាន់ថ្នាក់ (៤)ការបន្តពង្រឹងសមត្ថភាពមន្ត្រីគយនិងរដ្ឋាករក្នុងការកសាងសំណុំរឿងស្នើសុំចោទប្រកាន់និងដាក់ទោសទណ្ឌតាមច្បាប់ និង(៥)ការបន្តផ្សព្វផ្សាយរំលឹកដល់វិស័យឯកជនពាក់ព័ន្ធឱ្យបានទៀងទាត់ពាក់ព័ន្ធនឹងនីតិវិធីបំពេញបែបបទគយ នីតិវិធីនៃការដឹកជញ្ជូនទំនិញ និងកាតព្វកិច្ច ព្រមទាំងការទទួលខុសត្រូវក្នុងការបង់ពន្ធអាករលើទំនិញនាំចេញនាំចូលទាំងស្រុងតាមបទប្បញ្ញត្តិជាធរមាន។

- ការពង្រឹងគុណភាពប្រព័ន្ធគ្រប់គ្រងហានិភ័យគយនិងប្រព័ន្ធព័ត៌មាន៖ រួមមាន (១)ការកែលម្អឱ្យបានទៀងទាត់នូវប្រភេទលក្ខណៈវិនិច្ឆ័យជ្រើសរើសហានិភ័យគន្លឹះសម្រាប់ច្រកក្រហម (២)ធ្វើបច្ចុប្បន្នភាពឱ្យបានទៀងទាត់នូវកម្រិតហានិភ័យរបស់ធុរជនក្នុងប្រព័ន្ធគ្រប់គ្រងភាពជឿជាក់លើធុរជន (TCMS) និងទំនិញ (៣)បន្តពង្រីកភាពគ្របដណ្តប់នៃប្រព័ន្ធគ្រប់គ្រងទិន្នន័យហានិភ័យគយ (CRMDS) (៤)បន្តលើកកម្ពស់គុណភាពប្រព័ន្ធ CRMDS និង TCMS តាមរយៈការកែលម្អមុខងារនិងសូចនាករហានិភ័យ (៥)ពិនិត្យលទ្ធភាពលើកសំណើវិសោធនកម្មមាត្រា ៨ នៃអនុក្រឹត្យស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការគ្រប់គ្រងហានិភ័យ ដើម្បីកាត់បន្ថយមុខទំនិញមួយចំនួនដែលត្រូវចូលច្រកក្រហម និង(៦)ពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការនិងកិច្ចសហការរបស់/រវាងអង្គភាពគយមានសមត្ថកិច្ចជាពិសេសពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពអង្គភាពគ្រប់គ្រងហានិភ័យរបស់ស្ថាប័នរាជរដ្ឋាភិបាលផ្សេងទៀត ក្នុងការវាយតម្លៃអនុលោមភាពធុរជនដែលស្ថិតក្រោមការគ្រប់គ្រងគោលនយោបាយរបស់ខ្លួន។

- ការពង្រឹងប្រសិទ្ធភាពនៃការត្រួតពិនិត្យរូបវន្តលើទំនិញ៖ រួមមាន (១)ការអនុវត្តឱ្យបានពេញលេញនូវបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការត្រួតពិនិត្យប្រកបដោយជំនាញវិជ្ជាជីវៈ (២)ការបង្កើតអង្គភាពឯកទេសត្រួតពិនិត្យលើមុខសញ្ញាហានិភ័យខ្ពស់ និង(៣)បន្តជំរុញលើកកម្ពស់ការយល់ដឹងនិងការទទួលខុសត្រូវរបស់ធុរជននូវច្បាប់និងបទប្បញ្ញត្តិគយជាធរមានឱ្យបានទៀងទាត់ ជាពិសេសនូវនីតិវិធីនៃការត្រួតពិនិត្យទំនិញនៅដើមទី កណ្តាលទី និងចុងទី។

- ការពង្រឹងប្រសិទ្ធភាពនៃការធ្វើសវនកម្មក្រោយពេលបញ្ចេញទំនិញពីគយ (PCA)៖ រួមមាន (១)ការបន្តពង្រីកអង្គភាព PCA ដែលត្រូវចុះតាមអាជីវកម្មដ្ឋានធុរជន (២)ការបន្តពង្រីកភាពគ្របដណ្តប់យន្តការ PCA (៣)ការពង្រឹងសមត្ថភាពមន្ត្រី PCA និង(៤)ការបន្តការលើកកម្ពស់ការយល់ដឹងរបស់ធុរជនពីយន្តការ PCA។

- ការពង្រឹងសមត្ថភាពការងារបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ៖ រួមមាន (១)ការលើកទឹកចិត្តដល់មន្ត្រីគយមានសមត្ថកិច្ចបង្ក្រាបអំពើរត់គេចពន្ធ ឱ្យអនុវត្តការងាររបស់ខ្លួនតាមរូបភាពភ្លៀងរលឹម និងប្រកបដោយធន្ទះដាច់ខាត (២)ពង្រឹងការស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងចរាចរ ឬសន្និធិទំនិញកំណត់ពិសេសនៅតាមឃ្លាំងទំនិញ អាជីវកម្មដ្ឋាន ឬកន្លែងផ្សេងទៀត ជាពិសេស ផលិតផលគេលសិលានិងយានយន្ត (៣)លើកកម្ពស់កាតព្វកិច្ចនៃការរក្សាការសម្ងាត់វិជ្ជាជីវៈរបស់មន្ត្រីគយមានសមត្ថកិច្ច ជាពិសេស ព័ត៌មានហានិភ័យសម្ងាត់សម្រាប់សំណូមពរនៃការងារបង្ក្រាបបទល្មើស (៤) ពង្រឹងយន្តការឃ្លាំមើលនិងវាយតម្លៃអនុលោមភាពនៃការប្រើប្រាស់ទំនិញមួយចំនួនតាមគម្យដ្ឋានដែលបានអនុគ្រោះ (៥)ពង្រឹងប្រសិទ្ធភាពនៃការបង្ការ និងទប់ស្កាត់បទល្មើសឆ្លងដែនតាមច្រករបៀងមិនផ្លូវការនានានិងតាមផ្លូវសមុទ្រ (៦)កែសម្រួលនិងពង្រឹងកិច្ចដំណើរការឡើងវិញនូវអង្គភាពអន្តរស្ថាប័ននានា ក្រោមបញ្ញត្តិនៃលិខិតបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការងារទប់ស្កាត់និងបង្ក្រាបអំពើរត់គេចពន្ធជាធរមាន (៧)ការដាក់ឱ្យប្រើប្រាស់នូវលតាប័ត្រពិសេសសម្រាប់យានយន្តដែលត្រូវបាននាំចូលដោយពន្ធនិងអាករជាបន្ទុករបស់រដ្ឋ (៨)បង្កើតនិងដាក់ឱ្យដំណើរការនូវយន្តការផ្ទៀងផ្ទាត់អនុលោមភាពច្បាប់នៃយានយន្ត ជាពិសេសលើកាតព្វកិច្ចពន្ធ លតាប័ត្រ និងស្លាកលេខយានយន្តតាមដងផ្លូវនិងតាមអាជីវកម្មដ្ឋានឱ្យបានទៀងទាត់ (៩)កែលម្អប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងការផ្ទៀងផ្ទាត់អនុលោមភាពយានយន្ត និងធ្វើការអង្កេតអនុលោមភាពយានយន្តឯកជនដោយមានកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន (១០)កសាងផែនការសកម្មភាពបង្ក្រាបអំពើរត់គេចពន្ធដោយឡែកពីគ្នាតាមសូចនាករ តាមមុខសញ្ញា និងតាមពេលកំណត់នីមួយៗ អនុលោមតាមបទប្បញ្ញត្តិជាធរមាន (១១)កែលម្អប្រសិទ្ធភាពនៃការផ្លាស់ប្តូរព័ត៌មានរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ សម្រាប់គោលបំណងបង្ក្រាបអំពើរត់គេចពន្ធ (១២)ការប្រើប្រាស់យន្តការភាពជាដៃគូគយ-ផ្នែកឯកជនសម្រាប់សំណូមពរនៃការប្រយុទ្ធប្រឆាំងអំពើរត់គេចពន្ធ (១៣)ពង្រឹងប្រសិទ្ធភាពនៃកិច្ចសហការរវាងរដ្ឋបាលគយជាមួយស្ថាប័នមានសមត្ថកិច្ចផ្សេងទៀត និង(១៤)បន្តកិច្ចសហការជាមួយសមភាគីគយបរទេសជាពិសេសប្រទេសជិតខាងក្នុងការងារផ្លាស់ប្តូរព័ត៌មានហានិភ័យដែលជាតម្រូវការចាំបាច់ក្នុងការកំណត់បទល្មើសគយ។

- ការពង្រឹងអនុលោមភាពគោលការណ៍ WTO ពាក់ព័ន្ធនឹងតម្លៃគិតពន្ធគយ៖ រួមមាន (១) ការកែលម្អគុណភាពនៃតារាងតម្លៃចម្លងការសម្រាប់ការពិចារណា (២)ការពង្រឹងសមត្ថភាពអង្គភាពគ្រប់គ្រងតម្លៃចម្លងការ និង(៣)ការប្រើប្រាស់យន្តការ PCA ក្នុងការរកបទល្មើសពាក់ព័ន្ធនឹងតម្លៃគិតពន្ធគយ។

-ការពង្រឹងប្រសិទ្ធភាពនៃការចែករំលែកព័ត៌មានរវាងអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ៖ រួមមាន (១)ការកសាងអនុស្សារណៈនៃការយោគយល់គ្នារវាងអង្គភាពទាំងពីរដោយរក្សាឱ្យបាននូវការសម្ងាត់វិជ្ជាជីវៈតាមបទប្បញ្ញត្តិជាធរមាន និង(២)ការកែសម្រួលសមាសភាពក្រុមការងារអន្តរអគ្គនាយកដ្ឋានសម្រាប់កិច្ចសហការគយ-ពន្ធដារ។

- ការពង្រឹងសមត្ថភាពនិងគ្របដណ្តប់នៃប្រព័ន្ធអាស៊ីគូដា៖ រួមមាន (១)ការជំរុញពង្រីកភាពគ្របដណ្តប់នៃប្រព័ន្ធ និង(២)ការបំពេញបន្ថែមនូវមុខងារនានារបស់ប្រព័ន្ធ។

- ការជំរុញប្រសិទ្ធភាពនៃការអនុវត្តប្រព័ន្ធបញ្ចរជាតិតែមួយ៖ រួមមាន (១)បន្តកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានាកសាងផែនការសកម្មភាពលម្អិត ដើម្បីឈានទៅអនុវត្តប្រព័ន្ធនេះឱ្យបានពេញលេញ និង(២)ជំរុញអនុវត្តគោលការណ៍មូលដ្ឋានទាំង៣នៃប្រព័ន្ធបញ្ចរតែមួយ៖ ការដាក់ឯកសារតែម្តង ការត្រួតពិនិត្យតែម្តង និងការអនុញ្ញាតឱ្យយកទំនិញចេញតែម្តង (Single Submission-SS, Single Processing-SP and Single Release-SR) តាមបទប្បញ្ញត្តិជាធរមាន។

- ការពង្រឹងប្រសិទ្ធភាពការិយាល័យនាវាចរគយ៖ រួមមាន (១)ការបង្កើតនិងដាក់ឱ្យដំណើរការអង្គភាពបង្ក្រាបបទល្មើសគយ ទទួលបន្ទុកតំបន់ឆ្នេរសមុទ្រនិងប្រព័ន្ធទន្លេដែលមានធនធានមនុស្សនិងមធ្យោបាយការងារសមស្រប និង(២)ធ្វើការសិក្សានិងវាយតម្លៃពីការគំរាមកំហែងនិងហានិភ័យនានាពាក់ព័ន្ធនឹងប្រតិបត្តិការអំពើរត់ពន្ធតាមផ្លូវទឹករបស់អង្គភាពនាវាចរគយ និងលើកឡើងនូវជម្រើសនានាដើម្បីដោះស្រាយ។

- ការពង្រឹងប្រសិទ្ធភាពយន្តការភាពជាដៃគូរវាងគយនិងផ្នែកឯកជន៖ រួមមាន (១)ការលើកកម្ពស់ការយល់ដឹងពីតួនាទីរបស់វិស័យឯកជនពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្ម (២)ការលើកទឹកចិត្តបន្ថែមទៀតដល់ធុរជនដែលមានអនុលោមភាពខ្ពស់ ធ្វើជាដៃគូជាមួយគយក្នុងការពិគ្រោះយោបល់ដោះស្រាយបញ្ហាប្រឈមនានាពាក់ព័ន្ធនឹងរដ្ឋបាលគយ។

- ការពង្រីកសក្តានុពលនៃប្រភពចំណូលគយមួយចំនួន៖ រួមមាន (១)ការដាក់ឱ្យដំណើរការពេញលេញសាខាគយនិងរដ្ឋាករក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម និងការចាត់វិធានការប្រឆាំងអំពើរត់គេចពន្ធក្នុងតំបន់ទាំងនោះ និង(២)ការបន្តភាពទន់ភ្លន់លើមុខទំនិញវេទយិតភាពមួយចំនួនដើម្បីរក្សា/ពង្រីកប្រភពចំណូល។

**១៤**- វិធានការអភិបាលកិច្ចសំខាន់ៗមានដូចខាងក្រោម៖

- ការគ្រប់គ្រងអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤៖ រួមមាន (១)ការបង្កើតនិងដាក់ឱ្យដំណើរការក្រុមការងារគ្រប់គ្រងការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ និង(២)ការកែលម្អទម្រង់របាយការណ៍វឌ្ឍនភាពដើម្បីរលេចនូវខ្លឹមសារចាំបាច់នានាសម្រាប់បង្កការងាយស្រួលដល់ការវិភាគ។

- ការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តក្រមសីលធម៌និងកិរិយាមាយាទគយ និងការលើកកម្ពស់សុចរិតភាពក្នុងស្ថាប័នគយ៖ រួមមាន (១)ការពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងប្រអប់តវ៉ាគយ (២)ការពង្រឹងប្រសិទ្ធភាពនៃកិច្ចដំណើរការការិយាល័យសវនកម្មផ្ទៃក្នុង (៣)ការបង្កើតក្រុមប្រឹក្សាវិន័យរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សម្រាប់ដោះស្រាយរាល់ភាពអសកម្មនានារបស់មន្ត្រីគយនិងរដ្ឋាករក្នុងការបំពេញភារកិច្ចនិងកាតព្វកិច្ចរបស់ខ្លួន និង(៤)លើកកម្ពស់ការយល់ដឹងនិងការចូលរួមអនុវត្តនូវសេចក្តីប្រកាសទីក្រុងអារ៉ូសាស្តីពីសុចរិតភាពក្នុងរដ្ឋបាលគយតាមភារកិច្ចនិងកាតព្វកិច្ចរបស់មន្ត្រីគយនិងរដ្ឋាករគ្រប់រូបតាមបទប្បញ្ញត្តិជាធរមាន។

- ការលើកទឹកចិត្តមន្ត្រីគយនិងរដ្ឋាករ៖ រួមមាន (១)ការអនុវត្តឱ្យបានទៀងទាត់នូវការលើកសំណើសុំលើកទឹកចិត្តរបស់អង្គភាពគយនិងរដ្ឋាករគ្រប់ជាន់ថ្នាក់តាមបទប្បញ្ញត្តិជាធរមាន (២)ការលើកកម្ពស់ការយល់ដឹងដល់មន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធនឹងយន្តការលើកទឹកចិត្តជាធរមាន និង(៣)ការចាត់វិធានការលើកទឹកចិត្តដល់ក្រុមមន្ត្រីមានស្នាដៃឱ្យបានទៀងទាត់។

- ការដាក់ទោសទណ្ឌមន្ត្រីគយនិងរដ្ឋាករ៖ រួមមាន (១)ការអនុវត្តឱ្យបានទៀងទាត់លើការលើកសំណើដាក់ទោសទណ្ឌរបស់អង្គភាពគយនិងរដ្ឋាករគ្រប់ជាន់ថ្នាក់តាមបទប្បញ្ញត្តិជាធរមាន (២) លើកកម្ពស់ការយល់ដឹងដល់មន្ត្រីគយនិងរដ្ឋាករពាក់ព័ន្ធយន្តការដាក់ទោសទណ្ឌជាធរមាន និង(៣) ការចាត់វិធានការដាក់ទោសទណ្ឌដល់ក្រុមមន្ត្រីគយ ដែលមានភាពអសកម្មក្នុងការអនុវត្តនូវកាតព្វកិច្ចនិងភារកិច្ចរបស់ខ្លួនតាមបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានឱ្យបានទៀងទាត់។

- ការកសាងនិងអនុវត្តជំហានដំបូងនៃយុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយ ២០១៤-២០១៨៖ រួមមាន (១)ការកសាងផែនការជាយុទ្ធសាស្ត្រ និង(២)ការគ្រប់គ្រងអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់និងទំនើបកម្មគយ ២០១៤-២០១៨។

## ទី៣-<u>អគ្គនាយកដ្ឋាននានាពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ</u>

**១៥**- រៀបចំច្បាប់និងលិខិតបទដ្ឋានដូចខាងក្រោម៖

- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។
- រៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីគ្រប់គ្រងអាជីវកម្មកាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ។
- សិក្សា និងពិនិត្យឡើងវិញព្រះរាជក្រមលេខជស/រកម/០៦៩៦/០៣ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈនិងព្រះរាជក្រឹត្យលេខនស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីរៀបចំធ្វើវិសោធនកម្ម។
- រៀបចំសារាចរណែនាំស្តីពីការពង្រឹងការគ្រប់គ្រងចំណូល និងត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យា ឬសៀវភៅបន្ទុកការធ្វើអាជីវកម្ម សេវាកម្មទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។
- រៀបចំ និងកែសម្រួលប្រកាសរួម ឬប្រកាសអន្តរក្រសួង សារាចរណែនាំ និងលិខិតបទដ្ឋានផ្សេងទៀត ដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ ជាពិសេសការរៀបចំកម្រងសេវាសាធារណៈដែលកំណត់អំពីតម្លៃសេវា រយៈពេលនៃការផ្តល់សេវានិងសុពលភាពនៃសេវា និងការផ្តល់រង្វាន់លើកទឹកចិត្តរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ។

**១៦**- ជំរុញអនុវត្តឱ្យមានប្រសិទ្ធភាពច្បាប់និងលិខិតបទដ្ឋាន និងយន្តការមានស្រាប់៖

- បន្តជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាពនូវច្បាប់ និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ និងការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធ។
- ពង្រឹងយន្តការគ្រប់គ្រង និងប្រមូលចំណូលពីកាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ។
- ពង្រឹងយន្តការធានាសុចរិតភាពរបស់វិធាននៃល្បែងភ្នាល់ ដើម្បីធានាការអភិវឌ្ឍនៃវិស័យ។

- បង្កើតឱ្យមានយន្តការបង្ក្រាបការលេងល្បែងភ្នាល់គ្រប់ប្រភេទ ដែលគ្មានអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ពង្រឹងយន្តការគ្រប់គ្រង និងប្រមូលចំណូលពីអាជ្ញាប័ណ្ណ និងសេវាប្រឹក្សារបស់អាជីវកម្មអភិវឌ្ឍអចលនវត្ថុ សេវាកម្មជួញដូរ និងវាយតម្លៃអចលនវត្ថុ អាជីវកម្មបញ្ចាំ អាជីវកម្មធានារ៉ាប់រង។
- ផ្សព្វផ្សាយ និងបណ្តុះបណ្តាលប្រតិបត្តករ និងបញ្ញត្តករកាស៊ីណូ និងល្បែងភ្នាល់គ្រប់ប្រភេទ វិស័យធានារ៉ាប់រង វិស័យអចលនវត្ថុ វាយតម្លៃ និងបញ្ចាំ។

១៧- បន្តពង្រឹងការគ្រប់គ្រង និងប្រមូលចំណូលពីសេវាសាធារណៈតាមរយៈ៖

- បន្តពង្រឹងការអនុវត្តនូវវិធានការកែទម្រង់ការគ្រប់គ្រងកម្រៃសេវារដ្ឋបាលរបស់រដ្ឋ។
- បន្តជំរុញការដាក់ឱ្យអនុវត្តបង្កាន់ដៃជាតិសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធគ្រប់ប្រភេទនៅតាមគ្រប់បណ្តាក្រសួងស្ថាប័ន ។
- បន្តពង្រឹងការគ្រប់គ្រងចំណូល ជាពិសេសពីផលទុនប្រៃសណីយ៍និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលពីទិដ្ឋាការ ចំណូលពីលិខិតឆ្លងដែន តាមរយៈការអនុវត្តយន្តការតឹងទារចំណូល ដោយតម្រូវឱ្យក្រុមហ៊ុនទូរស័ព្ទទាំងអស់ និងក្រសួងស្ថាប័នត្រូវបង់ចំណូលដោយត្រង់ទៅក្នុងគណនីថវិកាជាតិនៅធនាគារជាតិនៃកម្ពុជា។
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពីចំណូលសេវាសាធារណៈ និងចាត់វិធានការតឹងទារបំណុលទាំងអស់ឱ្យមានប្រសិទ្ធភាព។

១៨- បន្តពង្រឹងការគ្រប់គ្រង និងប្រមូលចំណូលពីទ្រព្យសម្បត្តិរដ្ឋ ៖

- ក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ដែលជាភាគីនៃកិច្ចសន្យាជួលទ្រព្យសម្បត្តិរដ្ឋក្រោមការកាន់កាប់របស់ខ្លួន ត្រូវជំរុញការប្រមូលចំណូលថ្លៃឈ្នួលឱ្យបង់បានទាន់ពេលវេលា និងចាត់វិធានការផាកពិន័យតាមលក្ខខណ្ឌនៃកិច្ចសន្យា។
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសម្បទាន និងពង្រឹងកិច្ចដំណើរការផ្តល់និងគ្រប់គ្រងកិច្ចសន្យាសម្បទានគ្រប់ប្រភេទទាំងអស់ ក្នុងគោលដៅពង្រឹងប្រសិទ្ធភាពនៃការប្រមូលចំណូលពីកិច្ចសន្យាសម្បទានគ្រប់ប្រភេទចូលថវិកាជាតិ។
- ក្រសួងរ៉ែ និងថាមពល ត្រូវបើកទូលាយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយប្រើប្រាស់យន្តការជាធរមាន និងថ្មីថែមទៀត ដើម្បីខិតខំគ្រប់គ្រង និងប្រមូលចំណូលសួយសារ រ៉ែសម្ភារៈសំណង់ ជាពិសេស ខ្សាច់ និងអាចម៍ដី និងភាគចំណែករបស់រដ្ឋពីការធ្វើអាជីវកម្មរ៉ែឱ្យអស់សក្តានុពលចំណូល។
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពន្លឿនការរៀបចំបទដ្ឋាន និងយន្តការ ដើម្បីគ្រប់គ្រង និងប្រមូលចំណូលថ្លៃសម្បទានដីសេដ្ឋកិច្ច។
- សាលារាជធានី ខេត្តត្រូវពង្រឹងការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងពីវិស័យសាធារណៈផ្សេងទៀត ដោយត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ស្តី

ពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងតាមសារាចរណែនាំស្តីពីការពង្រឹងការគ្រប់គ្រងចំណូលពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងវិស័យសាធារណៈផ្សេងៗទៀត។

- បង្កើតយន្តការជាបន្ទាន់ ដើម្បីត្រួតពិនិត្យលើការយកថ្លៃសេវាចំណត ភាសីផ្សារ កំពង់ផ និងទីតាំងវិនិយោគទ្រព្យសម្បត្តិសាធារណៈដទៃទៀត ឱ្យស្របតាមសៀវភៅបន្ទុក ដោយត្រូវបិទផ្សាយតារាងតម្លៃនេះជាសាធារណៈ ដាក់ប្រអប់សំបុត្រផ្តល់ព័ត៌មាន។ ការត្រួតពិនិត្យនេះត្រូវធ្វើជាប្រចាំ និងត្រូវចាត់វិធានការឱ្យបានស្រួចស្រាវ និងឈានដល់ការលុបកិច្ចសន្យាអាជីវកម្មវិនិយោគ ចំពោះអាជីវករណាដែលបំពានកិច្ចសន្យា និងសៀវភៅបន្ទុក។
- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពីចំណូលទ្រព្យសម្បត្តិរដ្ឋ និងចាត់វិធានការតឹងទារបំណុលទាំងអស់ឱ្យមានប្រសិទ្ធភាព។

## ខ- ការអនុវត្តចំណាយថវិកា

**១៩**- ក្នុងឆ្នាំទី១នៃការអនុវត្ត **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ដែលផ្តោតជាពិសេសលើ "**វិស័យអាទិភាព ៤**" ក្នុងការឈានទៅសម្រេច "**គោលដៅយុទ្ធសាស្ត្រទាំង ៤**" រាជរដ្ឋាភិបាលនឹងត្រូវការចំណាយថវិកាសរុបចំនួន ១៤ ១៦៧ ៤៤៩ លានរៀល កើនឡើងប្រមាណ ១៣,១% ស្មើនឹង ២០,៦៥% នៃផ.ស.ស. គឺកើនឡើង ០,២៨% នៃផ.ស.ស. ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣។ ចំណាយចរន្តថវិកាថ្នាក់ជាតិ មានចំនួន ៨ ២៦៨ ៧០៣ លានរៀល គឺមានកំណើនប្រមាណ ១៤,៦% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ និងប្រមាណ ១៥,៣% ធៀបនឹងការប៉ាន់ស្មានអនុវត្តឆ្នាំ២០១៣ ត្រូវជា ១២,០៥% នៃ ផ.ស.ស.។ **ចំណាយមូលធនថ្នាក់ជាតិ** ត្រូវបានគ្រោងចំនួន ១ ៨៦៦ ៩២៤ លានរៀល មានសមាមាត្រប្រមាណ ១៣,៧% នៃចំណាយថវិកាថ្នាក់ជាតិសរុប និងមានកំណើនប្រមាណ ៧,៩% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៣ ត្រូវជា ២,៧២% នៃ ផ.ស.ស.។

**២០**- ទន្ទឹមនឹងនេះ ដើម្បីធានាឱ្យថវិកាឆ្នាំ២០១៤ ក្លាយជាឧបករណ៍ប្រកបដោយប្រសិទ្ធភាពពិតប្រាកដសម្រាប់អនុវត្តកម្មវិធីនយោបាយនិងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ការគ្រប់គ្រងការអនុវត្តថវិកាក្នុងនោះ ការគ្រប់គ្រងការអនុវត្តចំណាយត្រូវតែហ្មត់ចត់ និងម៉ឺងម៉ាត់ ដោយត្រូវពង្រឹងការគោរពច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុដទៃទៀត ជាពិសេស ការអនុវត្តចំណាយត្រូវមានប្រសិទ្ធភាព ចំទិសដៅអាទិភាពពិតប្រាកដ មានភាពសន្សំសំចៃខ្ពស់ និងស្ថិតក្នុងរង្វង់នៃលទ្ធភាពដែលមាន។ ទន្ទឹមនឹងនេះ ត្រូវជំរុញអនុវត្តឱ្យបានជោគជ័យឆាប់រហ័ស នូវបណ្តាផែនការសកម្មភាព និងវិធានការកែលម្អការគ្រប់គ្រងថវិកា និងបន្តដាក់ចេញនូវផែនការសកម្មភាពនិងវិធានការថ្មីៗទៀត ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងការអនុវត្តតាមទិសដៅដូចបានលើកឡើងខាងលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមគូសរំលេចនូវបណ្តានីតិវិធី និងវិធានការអនុវត្តដូចតទៅ:

## ខ.១-ការរៀបចំ និងការអនុវត្តកម្មវិធីចំណូល-ចំណាយ

**២១**- ដើម្បីឱ្យការអនុវត្តថវិកាប្រកបដោយភាពជឿទុកចិត្តបាន និងប្រព្រឹត្តទៅដោយរលូន ជាពិសេស ដើម្បីធានាការឆ្លើយតបទៅនឹងតម្រូវការសាច់ប្រាក់បានទាន់ពេលវេលា គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ ត្រូវពង្រឹងភាពជាម្ចាស់ក្នុងការរៀបចំគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស សម្រាប់រយៈពេលពេញ១ឆ្នាំ ដែលមានបែងចែកលម្អិតទៅតាមខែ និងទៅតាមគំរូដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃតម្រូវការចំណាយជាក់ស្តែង (តាមប្រតិទិននៃផែនការសកម្មភាពការងារនិងផែនការលទ្ធកម្ម) និងក្នុងក្របខ័ណ្ឌនៃឥណទានដែលត្រូវបានកំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។ ក្រសួង-ស្ថាប័ន ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា) ដោយឡែក មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវផ្ញើកម្មវិធីចំណូល-ចំណាយដែលបានរៀបចំ ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមួយច្បាប់ ដើម្បីមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបូកសរុបរួចផ្ញើមកអគ្គ-នាយកដ្ឋានថវិកា និងទៅក្រសួង-ស្ថាប័ន ដែលជាខ្សែបណ្តោយរបស់ខ្លួនមួយច្បាប់សម្រាប់ការគ្រប់គ្រង និងតាមដានការអនុវត្ត។ ក្រោយពីទទួលបានកម្មវិធីចំណូល-ចំណាយដែលស្នើឡើងដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវពិនិត្យ និងវាយតម្លៃលើអាទិ-ភាពនៃតម្រូវការនិងលទ្ធភាពចំណូលដែលអាចប្រមូលបាន ដើម្បីដាក់ចេញជាកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស ទៅតាមមាតិកាថវិកាសម្រាប់ការអនុវត្ត។

**២២**- ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសឱ្យកាន់តែបានត្រឹមត្រូវនិងសុក្រឹត ព្រមទាំងការអនុវត្តឱ្យបានម៉ឺងម៉ាត់តាមកម្មវិធីចំណូល-ចំណាយនេះគឺជាប្រការចាំបាច់បំផុត។ ដូច្នេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ និងអគ្គនាយកដ្ឋាននិងនាយកដ្ឋានពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវអភិក្រមការងារដូចខាងក្រោម៖

<u>ការរៀបចំកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស</u>

- នៅរៀងរាល់ថ្ងៃទី២០នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គ-នាយកដ្ឋានរតនាគារជាតិ នូវរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្ត ដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១ និងខែទី២ និងការប៉ាន់ស្មានអនុវត្តខែទី៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ប្រសិនបើចាំបាច់។
- ដោយឡែកមន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវ ផ្ញើរបាយការណ៍ប៉ាន់ស្មានអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសកំពុងអនុវត្តដោយឆ្លុះបញ្ចាំងពីការអនុវត្តជាក់ស្តែងប្រចាំខែទី១ និងខែទី២ និងការប៉ាន់ស្មានអនុវត្តខែទី៣ ជាមួយនឹងការស្នើឡើងនូវការកែសម្រួលគម្រោងកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាសបន្ទាប់ប្រសិនបើចាំបាច់ ទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១៥នៃ

ខែនាចុងត្រីមាសនីមួយៗ ដើម្បីទុកពេលវេលាឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបូកសរុបរួចផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអង្គភាពគ្រប់គ្រងសាច់ប្រាក់ឱ្យបានមុនថ្ងៃទី២០នៃខែនាចុងត្រីមាសនីមួយៗ។

• នៅរៀងរាល់ថ្ងៃទី២៥នៃខែនាចុងត្រីមាសនីមួយៗ អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំប្រជុំពិភាក្សាជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីរៀបចំកម្មវិធីចំណូល-ចំណាយថវិកាថ្នាក់ជាតិសម្រាប់ត្រីមាសបន្ទាប់។ ផ្អែកលើមូលដ្ឋាននៃកម្មវិធីចំណូល-ចំណាយនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា) ត្រូវរៀបចំប្រកាសកម្មវិធីចំណូល-ចំណាយសម្រាប់ត្រីមាសបន្ទាប់ ទៅតាមមាតិកាថវិកា ក្នុងកម្រិតឥណទានអតិបរមាសម្រាប់ក្រសួង-ស្ថាប័ននីមួយៗ និងមន្ទីរជំនាញរាជធានី-ខេត្តនីមួយៗ ដោយចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ និងគណៈអភិបាលរាជធានី-ខេត្ត។

<u>ការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស</u>

• អាណាប័កដើមខ្សែ ឬអាណាប័កតាមការប្រទានសិទ្ធិ ត្រូវចេញអាណត្តិបើកប្រាក់នៅក្នុងរង្វង់នៃកម្មវិធីចំណាយប្រចាំត្រីមាសរបស់ខ្លួន ហើយអគ្គនាយកដ្ឋានថវិកា មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត អគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគាររាជធានី-ខេត្ត ត្រូវចុះទិដ្ឋាការលើអាណត្តិបើកប្រាក់ និងត្រូវបើកជាសាច់ប្រាក់តែនៅក្នុងកម្រិតនៃកម្មវិធីចំណូល-ចំណាយ និងសាច់ប្រាក់ប្រចាំត្រីមាសនេះតែប៉ុណ្ណោះ។

<u>ការតាមដានការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស</u>

• អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួង-ស្ថាប័ន និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវផ្ញើរបាយការណ៍អនុវត្តចំណូល-ចំណាយប្រចាំខែមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី១៥នៃខែបន្ទាប់។

• អគ្គនាយកដ្ឋានរតនាគារជាតិ ត្រូវបញ្ជូនមកអគ្គនាយកដ្ឋានថវិកានូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ របាយការណ៍បុរេប្រទាន និងតារាងតុល្យភាពនៃគណនីប្រចាំខែ ដើម្បីឱ្យអគ្គនាយកដ្ឋានថវិកា តាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស ព្រមទាំងធ្វើការសន្និដ្ឋាន វាយតម្លៃនូវសភាពការណ៍អនុវត្តធៀបនឹងខែមុន ត្រីមាសមុននៃឆ្នាំនេះ និងប្រៀបធៀបទៅនឹងខែ ត្រីមាស ដូចគ្នានៃឆ្នាំមុន។

• រតនាគារនៅថ្នាក់មូលដ្ឋានត្រូវបញ្ជូនមកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនូវរបាយការណ៍ចំណូល-ចំណាយថវិកាប្រចាំខែ ដើម្បីឱ្យមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុតាមដានបូកសរុបចំណូល-ចំណាយថវិកាប្រចាំខែ ប្រចាំត្រីមាស និងធ្វើរបាយការណ៍ផ្ញើមកអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ខ.២- ការផ្តល់ធានាចំណាយ

**២៣**-ទាំងការស្នើសុំ និងការផ្តល់ធានាចំណាយនៃថវិកាកម្មវិធី និងថវិកាមិនមែនកម្មវិធី ត្រូវអនុវត្តទៅតាមប្រភេទចំណាយធំៗបី ដូចខាងក្រោម៖

- **ចំណាយបន្ទុកបុគ្គលិក(ជំពូក៦៤)** ចំពោះចំណាយដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈ ពុំតម្រូវឱ្យមានការស្នើសុំធានាចំណាយដាច់ដោយឡែកទេ គឺត្រូវបោះផ្សាយអាណត្តិបើកប្រាក់តែម្តង ដោយឈរលើមូលដ្ឋានឥណទានដែលមាន។ ក្នុងន័យនេះ ដោយថាហេតុក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចនឹងចាត់វិធានការបង្កកឥណទានចំណាយជំពូកផ្សេងទៀត ក្នុងករណីពិនិត្យឃើញថាឥណទានថវិកាបន្ទុកបុគ្គលិករបស់ក្រសួង-ស្ថាប័ន មានមិនគ្រប់ចំនួន ស្របតាមការគណនាដោយផ្អែកលើស្ថានភាពដែលមានទិដ្ឋាការបញ្ជាក់ពីចំនួនក្របខ័ណ្ឌ និងកាំប្រាក់ពីក្រសួងមុខងារសាធារណៈ។ ដូចនេះ ក្នុងអំឡុងពេលអនុវត្ត ក្រសួង-ស្ថាប័នត្រូវយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ ក្នុងការគ្រប់គ្រងឥណទានបន្ទុកបុគ្គលិកនេះឱ្យគ្រប់គ្រាន់ ដើម្បីជៀសវាងការរាំងស្ទះដល់ការបើកផ្តល់ប្រាក់បៀវត្ស។ ក្នុងករណីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដឹងថា ឥណទានជំពូក៦៤មានការខ្វះខាត និងមានតម្រូវការបន្ថែម ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ពាក់ព័ន្ធ ត្រូវខិតខំសន្សំចំណាយមិនមែនបន្ទុកបុគ្គលិក ដើម្បីធ្វើនិយ័តកម្មបំពេញបន្ថែមចំណាយបន្ទុកបុគ្គលិក។ ឥណទានថវិកាជំពូក ៦៤ នឹងមិនត្រូវបានអនុញ្ញាតឱ្យមានការបន្ថែមឥណទានជូនទេ វៀរលែងតែក្នុងករណីមានតម្រូវការបន្ថែមដោយសាររាជរដ្ឋាភិបាលមានការកែប្រែគោលនយោបាយ ឬផ្តល់គោលការណ៍ថ្មីជាពិសេសក្នុងអំឡុងឆ្នាំអនុវត្ត ឬតែក្នុងករណីដែលតម្រូវការបន្ថែមនោះមានពាក់ព័ន្ធនឹងការកើនចំណូលថ្មីបន្ថែមពីលើផែនការប៉ុណ្ណោះ។

- **ចំណាយដែលមិនតម្រូវឱ្យអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ** រួមមាន ចំណាយតាមរយៈរដ្ឋទេយ្យបុរេប្រទាន ចំណាយលើអគ្គិសនី ទឹក ទូរស័ព្ទ និងចំណាយឧបត្ថម្ភផ្សេងៗដែលមានគោលការណ៍កំណត់រួចហើយ ពុំតម្រូវឱ្យមានការស្នើសុំធានាចំណាយដោយឡែកទេ។ ចំពោះចំណាយប្រភេទនេះ អាណាប័កត្រូវធ្វើសាលាកប័ត្រ និងបោះផ្សាយអាណត្តិបើកប្រាក់សុំទូទាត់តែម្តង។ ទោះជាយ៉ាងនេះក្តី ប្រការនេះក៏មិនមានន័យថានឹងទទួលបានការទូទាត់ ឬការបើកផ្តល់តាមសំណើជាស្វ័យប្រវត្តិនោះទេ។ ក្នុងន័យនេះ ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវមានការយកចិត្តទុកដាក់ប្រកបដោយការទទួលខុសត្រូវខ្ពស់ក្នុងការរៀបចំសំណើដោយមានភ្ជាប់មកជាមួយនូវឯកសារ និងលិខិតយុត្តិការគ្រប់គ្រាន់ស្របទៅតាមនីតិវិធីទូទាត់ ឬបើកផ្តល់។

- **ចំណាយដែលតម្រូវឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈ** តម្រូវឱ្យមានការស្នើសុំធានាចំណាយ។ ក្នុងការធានាចំណាយក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្ត ត្រូវគោរពឱ្យបាននូវគោលការណ៍សំខាន់ជាសារវន្តដូចខាងក្រោម៖

- មុខចំណាយត្រូវស្របទៅតាមផែនការលទ្ធកម្ម។ ចំពោះចំណាយនេះ បើមិនមានកត់ត្រាក្នុងផែនការលទ្ធកម្មទេ មិនអនុញ្ញាតឱ្យស្នើសុំឬផ្តល់ការធានាចំណាយឡើយ។

- មុខចំណាយដែលស្នើសុំ ត្រូវមានឥណទានគ្រប់គ្រាន់សម្រាប់អនុវត្ត។ មិនអនុញ្ញាតជាដាច់ខាតចំពោះការចេញធានាចំណាយដោយគ្មានឥណទាន។ ក្នុងន័យនេះ ការស្នើសុំធានាចំណាយត្រូវគិតដល់:

+ ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយដែលបានធានារួច

+ ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់មុខចំណាយ ដែលចាំបាច់ខានមិនបាន ដែលអាចកើតមាននាពេលខាងមុខ

+ ការរក្សាឥណទានថវិកាទុកសម្រាប់ទូទាត់ចំណាយរដ្ឋទេយ្យបុរេប្រទាន និងចំណាយថវិកាបុរេប្រទានដោយរាប់ទាំងចំណាយថវិកាបុរេប្រទានក្នុងឆ្នាំកន្លងទៅផងដែរប្រសិនបើមាន។

- គម្រោងចំណាយត្រូវមានភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ដោយត្រូវមានបទដ្ឋានបច្ចេកទេស ឬយថាប្រភេទច្បាស់លាស់ ដែលអាចជាមូលដ្ឋានសម្រាប់ការពិនិត្យអំពីភាពសមស្របខាងតម្លៃ, និងអំពីភាពចាំបាច់នៃគម្រោង ឬការងារ។ ក្នុងការលើកសំណើសុំធានាចំណាយ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ចាំបាច់ត្រូវគិតគូរឱ្យបានស្រេចបាច់អំពីតម្លៃទីផ្សារជាក់ស្តែង អំពីបរិមាណ និងគុណភាពនៃទំនិញនិងសំណង់ ដែលត្រូវធ្វើកិច្ចលទ្ធកម្មសាធារណៈ មុននឹងសុំធានាចំណាយមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងផ្តល់ធានាចំណាយទៅតាមតម្លៃទីផ្សារជាក់ស្តែង។

- គម្រោងចំណាយមានភាពចាំបាច់ ដែលផ្តល់ផលប្រយោជន៍ពិតប្រាកដ សម្រាប់ឱ្យក្រសួង-ស្ថាប័នសម្រេចបេសកកម្មការងាររបស់ខ្លួន ដោយជៀសវាងឱ្យបាននូវការបង្កើតចំណាយមិនចាំបាច់ និងខ្ជះខ្ជាយ។

- ការផ្តល់ធានាចំណាយ និងការផ្តល់ទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវតែមានការស្នើសុំជាលាយល័ក្ខណ៍អក្សរពីអាណាប័កដើមខ្សែ ឬអាណាប័កផ្ទេរសិទ្ធិជាដាច់ខាត ដោយរាប់ទាំងចំណាយទាំងឡាយ ដែលមានកត់ត្រាទុកនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុផងដែរ ។

- ចំពោះចំណាយវិនិយោគ ការសុំនិងផ្តល់ធានាចំណាយត្រូវស្ថិតក្នុងវង្ង់ឥណទានថវិកាដែលបានអនុម័តមានលក្ខណៈកម្រិតកំណត់។

- ឥណទានដែលបានកាត់/សន្សំ ពីការប៉ាន់ប៉ាងតម្លៃនៃគម្រោងសុំធានាចំណាយរបស់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត នឹងត្រូវបង្កក មិនអនុញ្ញាតឱ្យចំណាយបន្ថែម ឬធ្វើនិយ័តកម្មសម្រាប់បម្រើឱ្យចំណាយផ្សេងទៀតឡើយ វៀរលែងតែមានការពន្យល់ច្បាស់លាស់អំពីសេចក្តីត្រូវការចាំបាច់បំផុតប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ ទំហំឥណទានដែលបានកាត់/សន្សំនេះ នឹងត្រូវកាត់បន្ថយជាស្វ័យប្រវត្តិពីកញ្ចប់ឥណទានថវិកាឆ្នាំបន្ទាប់របស់ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត។

- មិនត្រូវសុំនិងផ្តល់ធានាចំណាយទៅលើការអនុវត្តនូវសកម្មភាពដែលនាំឱ្យមានការជ្រើសរើសមន្ត្រីថ្មី ឬមន្ត្រីជាប់កិច្ចសន្យានៅក្នុងឆ្នាំដែលកំពុងអនុវត្ត ដោយគ្មានការគ្រោងទុកក្នុងថវិកា ឬគ្មានសេចក្តីសម្រេចពីរាជរដ្ឋាភិបាល។

- ក្នុងការសុំនិងផ្តល់ធានាចំណាយមិនត្រូវកាត់បន្ថយសកម្មភាពការងារ អនុកម្មវិធី ឬកម្មវិធីដែលបានអនុម័តរួចហើយនោះទេ លើកលែងតែមានការស្នើសុំពីសាមីក្រសួង-ស្ថាប័ន ដោយមានបញ្ជាក់ពីហេតុផល និងផលប៉ះពាល់ច្បាស់លាស់ ហើយធានាថាមិនធ្វើឱ្យប៉ះពាល់ដល់ការសម្រេចគោលដៅសូចនាករនៃគោលនយោបាយរបស់ក្រសួង-ស្ថាប័នដែលបានកំណត់ ឬគោលនយោបាយរបស់វិស័យ និងគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល។

## ខ.៣- ការធ្វើលទ្ធកម្មសាធារណៈ

២៤-គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ត្រូវគោរពឱ្យបានម៉ឺងម៉ាត់នូវបទប្បញ្ញត្តិ វិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មសាធារណៈដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្តិ ព្រមទាំងលិខិតបទដ្ឋានពាក់ព័ន្ធលទ្ធកម្មសាធារណៈជាធរមាន ដូចជាអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ សៀវភៅលទ្ធកម្មស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ សារាចរណែនាំលេខ០០៦ សហវ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០៧ ស្តីពីការរៀបចំផែនការលទ្ធកម្មឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ និងបទប្បញ្ញត្តិផ្សេងៗទៀតស្តីពីលទ្ធកម្មសាធារណៈ។ ទន្ទឹមនឹងនេះ ត្រូវយកចិត្តទុកដាក់បន្ថែមដូចខាងក្រោម៖

- ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ត្រូវរួសរាន់រៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៤ ផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ) ដើម្បីពិនិត្យ និងអនុម័តឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ មុនឆ្នាំអនុវត្តថវិកាជាកំហិត ស្របតាមខ្លឹមសារមាត្រា៣៥ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។
- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ ត្រូវធ្វើឡើងដោយចងជា"ឡូត៍លទ្ធកម្ម" ឬ"កញ្ចប់លទ្ធកម្ម" ចំពោះមុខសញ្ញាលទ្ធកម្មដែលមានលក្ខណៈបច្ចេកទេសដូចគ្នា ឬប្រហាក់ប្រហែលគ្នា ស្របតាមតម្រូវការជាក់ស្តែងរបស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត។
- ក្នុងករណីចាំបាច់ អនុញ្ញាតឱ្យធ្វើផែនការលទ្ធកម្មកែតម្រូវ។ រាល់ការកែតម្រូវផែនការលទ្ធកម្មដោយសារមិនមានពេលគ្រប់គ្រាន់សម្រាប់អនុវត្តកិច្ចលទ្ធកម្ម ឬដើម្បីតម្រូវតាមកិច្ចលទ្ធកម្មដែលបានអនុវត្តរួច ត្រូវហាមឃាត់។
- សម្រាប់ក្រសួង ស្ថាប័ន អង្គភាពតែមួយ ហាមបំបែកគម្រោង ជាគម្រោងតូចៗក្នុងគោលបំណងបំពានវិធីសាស្ត្រលទ្ធកម្ម ឬដើម្បីតម្រូវតាមសិទ្ធិសម្រេចរបស់ខ្លួន។
- ការអនុវត្តកិច្ចលទ្ធកម្មសាធារណៈត្រូវធ្វើឡើងឱ្យស្របតាមវិធីសាស្ត្រនិងប្រតិទិនដែលបានកំណត់នៅក្នុងផែនការលទ្ធកម្ម។ ឧទាហរណ៍ៈ ជាគោលការណ៍ ត្រូវអនុវត្តឱ្យបានដាច់ខាតចំពោះការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃក្នុងរយៈពេលយ៉ាងតិច៦០ថ្ងៃ សម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងយ៉ាងតិច៣០ថ្ងៃ សម្រាប់ការដេញថ្លៃដោយប្រកួតប្រជែងក្នុងស្រុក។ សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និង/ឬការពិគ្រោះថ្លៃ ត្រូវផ្សព្វផ្សាយជាលក្ខណៈចំហឱ្យបានជាដាច់ខាត តាមរយៈសារព័ត៌មានដែលប្រជាពលរដ្ឋទូទៅអាន និងតាមគេហទំព័ររបស់អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរបស់អង្គភាពសាមីនីមួយៗ។
- ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពដទៃទៀត ត្រូវថតចម្លងគ្រប់សេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និង/ឬ ការពិគ្រោះថ្លៃ ជូនអង្គភាពប្រឆាំងអំពើពុករលួយ។

• ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ត្រូវរៀបចំឯកសារដេញថ្លៃឱ្យសមស្របតាមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ដោយបញ្ជាក់ពីលក្ខខណ្ឌតម្រូវ និងលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកដេញថ្លៃឱ្យបានច្បាស់លាស់ និងត្រូវធានាផលិតឯកសារដេញថ្លៃឱ្យបានគ្រប់គ្រាន់សម្រាប់លក់ ឬផ្តល់ជូនអ្នកដេញថ្លៃដោយគ្មានការរើសអើង ជាពិសេស ត្រូវអនុវត្តការដេញថ្លៃតាមលក្ខណៈបើកចំហ និងលុបបំបាត់កិច្ចលទ្ធកម្ម ដែលគេនិយមហៅថា "ចងមុង"។ ការបង្កការលំបាក ឬ ការរារាំងណាមួយចំពោះការលក់ឯកសារដេញថ្លៃ និង/ឬ ឯកសារពិគ្រោះថ្លៃ ត្រូវជៀសវាងដាច់ខាត។

• តម្លៃកិច្ចសន្យាលទ្ធកម្មមិនអនុញ្ញាតឱ្យលើសឥណទានថវិកាដែលបានផ្តល់ការធានាចំណាយឡើយ។ ករណីចាំបាច់ត្រូវលើសពីឥណទានដែលបានផ្តល់ពេលធានាចំណាយ តាមសំណើរបស់ក្រសួង-ស្ថាប័ន អង្គភាពដែលផ្តល់ធានាចំណាយ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម(ករណីក្រោមសិទ្ធិសម្រេច) ត្រូវពិភាក្សាគ្នាដើម្បីរិះរកវិធានការដោះស្រាយដោយតម្លាភាពស្របតាមនីតិវិធីជាធរមាន។

• មិនអនុញ្ញាតឱ្យកាត់បន្ថយទំហំ បរិមាណ គុណភាព និងបទដ្ឋានបច្ចេកទេសសំណង់ ឬការងារថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ក្នុងគោលបំណងតម្រឹមតាមឥណទានដែលបានធានាចំណាយឡើយ។ក្នុងករណីចាំបាច់ត្រូវមានការកែប្រែទំហំ បរិមាណ គុណភាព និងបទដ្ឋានបច្ចេកទេសសំណង់ តាមសំណើរបស់ក្រសួង ស្ថាប័ន អង្គភាពដែលផ្តល់ធានាចំណាយ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ឬអង្គភាពលទ្ធកម្ម(ករណីក្រោមសិទ្ធិសម្រេច) ត្រូវពិភាក្សាគ្នាដើម្បីរិះរកវិធានការដោះស្រាយដោយតម្លាភាពស្របតាមនីតិវិធីជាធរមាន។

• ក្នុងករណីចាំបាច់ដែលតម្រូវឱ្យមានការផ្លាស់ប្តូរលក្ខណៈបច្ចេកទេសទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាដែលកំណត់ក្នុងកិច្ចសន្យា ត្រូវតែមានការឯកភាពឡើងវិញជាលាយល័ក្ខណ៍អក្សរពីគ្រប់ភាគីទាំងអស់ ដែលពាក់ព័ន្ធនឹងការចុះហត្ថលេខានិងអនុម័តលើកិច្ចសន្យា ។

• ក្នុងករណីការងារទទួលអនុវត្តដោយអង្គភាពរដ្ឋ ការទូទាត់ត្រូវរក្សាទឹកប្រាក់ចំនួន១០% នៃតម្លៃកិច្ចសន្យាសរុប ដើម្បីទុកជាការធានាគុណភាពជំនួសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យារហូតដល់ផុតរយៈពេលធានាគុណភាពទើបធ្វើការទូទាត់ជូនបង្គ្រប់បញ្ចប់ បន្ទាប់ពីមានកំណត់ហេតុប្រគល់ទទួលបញ្ជាក់ថាបានអនុវត្តត្រឹមត្រូវតាមកិច្ចសន្យា។

• គ្រប់ក្រសួង ស្ថាប័ន រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈរដ្ឋបាល និងអង្គភាពរដ្ឋដទៃទៀត ត្រូវផ្ញើរបាយការណ៍អនុវត្តលទ្ធកម្មប្រចាំត្រីមាស ឆមាស និងឆ្នាំ(តាមគំរូដែលបានកំណត់) មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (ចំពោះរដ្ឋបាលក្រុង ស្រុក ខណ្ឌ) ឱ្យបានទៀងទាត់។

• រាល់ការប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ឯកសារគតិយុត្តិនិងលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន ឬការពាក់ព័ន្ធនឹងអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការលទ្ធកម្មសាធារណៈ ត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងមាត្រា៦៥ដល់មាត្រា៧៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ អង្គភាពនិងបុគ្គលដទៃទៀត ដែលបានដឹងពីបទល្មើស

ពុករលួយទាំងឡាយណាដែលមានចែងក្នុងច្បាប់នេះ និងក្នុងច្បាប់និងបទប្បញ្ញត្តិជាធរមានដទៃទៀតនៃព្រះរាជាណាចក្រកម្ពុជា ត្រូវប្តឹងទៅអង្គភាព ឬការិយាល័យរាជធានី ខេត្ត ប្រឆាំងអំពើពុករលួយអំពីរឿងហេតុនៃបទល្មើសទាំងនេះ។

## ខ.៤ -ការប្រគល់ទទួល (ទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា)

**២៥**- ការប្រគល់ទទួលទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា គឺជាដំណាក់កាលបន្ទាប់ពីក្រសួង-ស្ថាប័ន បានអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីលទ្ធកម្មសាធារណៈ និងឯកសារគតិយុត្តិ និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ការប្រគល់ទទួល គឺពិនិត្យមើលពីភាពត្រឹមត្រូវ ទាំងមុខទំនិញ ឯកតា បរិមាណ តម្លៃ ប្រភព និងគុណភាព ព្រមទាំងផ្ទៀងផ្ទាត់មិនឱ្យលើសពីទឹកប្រាក់នៃការធានាចំណាយ និងមិនឱ្យខុសពីបទដ្ឋានបច្ចេកទេស និងយថាប្រភេទដែលបានធានាចំណាយ និងចុះកិច្ចសន្យាឡើយ។ ដូចនេះ ក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រដ្ឋមិនត្រូវបានអនុញ្ញាតឱ្យទទួលយកទំនិញ សំណង់ សេវាកម្ម ឬសេវាទីប្រឹក្សាជាដាច់ខាត ប្រសិនបើមិនមានកិច្ចសន្យា ឬប្រសិនបើទំនិញ សំណង់ សេវាកម្ម ឬសេវាកម្មទីប្រឹក្សា មិនត្រូវបានអនុវត្តបានគ្រប់ចំនួន និងត្រឹមត្រូវតាមលក្ខខណ្ឌនៃកិច្ចសន្យាទេ។

## ខ.៥ - ការទូទាត់ និងការបើកផ្តល់

**២៦**-ការទូទាត់គឺជាដំណាក់កាលចុងក្រោយនៃបរិបថចំណាយ។ ក្រោយពេលទំនិញត្រូវបានប្រគល់ទទួល ឬការងារត្រូវបានបំពេញរួចរាល់ហើយ អាណាប័កត្រូវចាត់ចែងទូទាត់តាមគោលការណ៍ និងនីតិវិធីដូចខាងក្រោមៈ

-ចំណាយថវិការបស់រដ្ឋត្រូវជម្រះបញ្ជីដោយអាណាប័ក ដែលជាអ្នកបោះផ្សាយអាណត្តិបើកប្រាក់។

- អាណត្តិបើកប្រាក់ត្រូវភ្ជាប់មកជាមួយនូវលិខិតយុត្តិការសម្រាប់គាំទ្រដល់ការទូទាត់ រួមមាន កិច្ចសន្យា វិក្កយបត្រ កំណត់ហេតុនៃការងារបច្ចេកទេស កំណត់ហេតុប្រគល់ទទួល ប័ណ្ណបញ្ចេញបញ្ចូលឃ្លាំង (ក្នុងករណីជាទំនិញ) កំណត់ហេតុត្រួតពិនិត្យលទ្ធផលការងារ និងតារាងសម្រង់ចំណាយថវិកា ជាដើម ។ អាណត្តិបើកប្រាក់ មិនត្រូវបានអនុញ្ញាតឱ្យបោះផ្សាយនោះទេ ប្រសិនបើលិខិតយុត្តិ-ការផ្លូវការមិនមានលក្ខណៈគ្រប់គ្រាន់និងត្រឹមត្រូវតាមនីតិវិធីហិរញ្ញវត្ថុ។

- អាណត្តិបើកប្រាក់ត្រូវធ្វើការទូទាត់និងបោះផ្សាយទៅតាមចំនួនទឹកប្រាក់ពិតប្រាកដ។

- អាណត្តិបើកប្រាក់ត្រូវធ្វើការទូទាត់និងបោះផ្សាយទៅតាមកម្មវិធីចំណាយដែលបានកំណត់។

- អាណត្តិបើកប្រាក់ត្រូវឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុជាមុន។

- អាណាប័ក ឬអាណាប័កផ្ទេរសិទ្ធិ ត្រូវណែនាំដល់អត្ថគាហកឱ្យបើកគណនីនៅធនាគារ ដើម្បីអគ្គនាយកដ្ឋានរតនាគារជាតិ និងរតនាគាររាជធានី-ខេត្ត អាចធ្វើការទូទាត់អាណត្តិបើកប្រាក់ដោយផ្ទាល់ទៅគណនីរបស់អត្ថគាហកតាមរយៈប្រព័ន្ធធនាគារ។

-អាណត្តិត្រូវបញ្ជូនមកដល់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនឱ្យហួសថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៤។

- អាណត្តិបើកប្រាក់ត្រូវបញ្ជូនមកអគ្គនាយកដ្ឋានរតនាគារជាតិ និង រតនាគាររាជធានី-ខេត្ត យ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤។ ដោយឡែក អគ្គនាយកដ្ឋានរតនាគារជាតិនឹងផ្តល់រយៈពេលអនុគ្រោះទូទាត់ប្រាក់សម្រាប់ថ្នាក់កណ្តាលរហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៥។ ក្រោយកាលបរិច្ឆេទនេះ អគ្គនាយកដ្ឋានរតនាគារជាតិ មិនទទួលអាណត្តិបើកប្រាក់ទេ ហើយអាណាប័កត្រូវបោះផ្សាយអាណត្តិបើកប្រាក់ថ្មីដោយប្រើប្រាស់ឥណទានថវិកាឆ្នាំបន្ទាប់។

-ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពចំណាយ និងការទទួលខុសត្រូវច្បាស់លាស់ ក្រសួង-ស្ថាប័នត្រូវខិតខំកាត់បន្ថយឱ្យបានជាអតិបរមា តាមដែលអាចធ្វើទៅបាននូវបែបបទផ្ទៃក្នុងក្នុងការត្រួតពិនិត្យឯកសារនៅក្នុងដំណាក់កាលទូទាត់នេះ។

**២៧**-រជ្ជទេយ្យបុរេប្រទានមានពីរប្រភេទគឺ ១)- រជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ដែលមានទឹកប្រាក់នៃជុំបង្វិល១ភាគ៨ លើ៣០%នៃឥណទានសរុបដែលជ្រើសរើសយកមកបង្កើតរជ្ជ-ទេយ្យបុរេប្រទាន និង ២)- រជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី ដែលមានទឹកប្រាក់នៃជុំបង្វិល១ភាគ៤ នៃទឹកប្រាក់សរុបសម្រាប់បង្កើតរជ្ជទេយ្យបុរេប្រទានថវិកាតាមកម្មវិធី ក្រោយពីបានដកចេញរួចហើយនូវឥណទានដែលទុកសម្រាប់ចំណាយតាមនីតិវិធីទូទាត់ត្រង់។ ទោះជារជ្ជទេយ្យបុរេប្រទានថវិកាមិនមែនកម្មវិធី ឬរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធីក៏ដោយ ចំនួនលើកនៃការទូទាត់អាចអនុញ្ញាតឱ្យធ្វើបានលើសពីចំនួនជុំបង្វិល អាស្រ័យទៅតាមចំណាយជាក់ស្តែងដែលបានអនុវត្ត ប៉ុន្តែមិនត្រូវមានចំនួនទឹកប្រាក់លើសចំនួនទឹកប្រាក់នៃជុំបង្វិល ជាពិសេសគឺត្រូវសុំបំពេញបេឡារជ្ជទេយ្យបុរេប្រទានឡើងវិញដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទូទាត់ផង និងដើម្បីកុំឱ្យស្ទះការងារផង។ រាល់ការសុំទូទាត់ និងការសុំបំពេញបេឡារជ្ជទេយ្យបុរេប្រទានត្រូវមានលិខិតយុត្តិការគ្រប់គ្រាន់ និងត្រឹមត្រូវអនុវត្តទៅតាមតារាងឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងស្តីពីការបង្កើតរជ្ជទេយ្យបុរេប្រទាន។ ជាមួយគ្នានេះដែរ គ្រប់ក្រសួង-ស្ថាប័នត្រូវពង្រឹងការអនុវត្តឱ្យបានម៉ឺងម៉ាត់នូវសារាចរណែនាំលេខ ០១៤សហវ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន និងសារាចរណែនាំបន្ថែមលេខ ០០៣សហវ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការចំណាយរជ្ជទេយ្យបុរេប្រទានថវិកាកម្មវិធី (សម្រាប់ថវិកាតាមកម្មវិធី) ជាពិសេសពាក់ព័ន្ធនឹងមុខសញ្ញាចំណាយតាមរយៈរជ្ជទេយ្យបុរេប្រទាន និងហាមដាច់ខាតការបំបែកប័ណ្ណចំណាយទៅតាមទីកន្លែង(គោលដៅចំណាយ) ពេលវេលា ទឹក-ប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយក្នុងគោលបំណងគេចវេះការអនុវត្តនីតិវិធីលទ្ធ-កម្ម ឬការប្រើប្រាស់រជ្ជទេយ្យបុរេប្រទានជំនួសការអនុវត្តនីតិវិធីលទ្ធកម្ម។

**២៨**-ការផ្តល់ថវិកាបុរេប្រទានត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិ គោលការណ៍ និងនីតិវិធីដែលមានចែងនៅក្នុងអនុក្រឹត្យលេខ១៥៥ អនក្រ បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយថវិកាចរន្តនិងចំណាយថវិកាវិនិយោគសាធារណៈ។ វៀរលែងតែមានបទបញ្ជាពីនាយករដ្ឋមន្ត្រី ឱ្យអនុវត្តការងារបន្ទាន់ដោយគ្មានការព្រាងទុក ការផ្តល់ថវិកាបុរេ-ប្រទានមិនត្រូវបានអនុញ្ញាតជាដាច់ខាត ប្រសិនបើសំណើសុំថវិកាបុរេប្រទានពុំមានភ្ជាប់មកជាមួយនូវលិខិតយុត្តិការផ្លូវការត្រឹមត្រូវ គ្រប់គ្រាន់ និងច្បាស់លាស់ទេ។ ការស្នើសុំនិងផ្តល់ថវិកាបុរេប្រទាន មិនអាចអនុវត្តបានដោយគ្មានឥណទានឡើយ។ បន្ទាប់ពីទទួលបានថវិកាបុរេប្រទានឥណទានថវិកាសម្រាប់មុខចំណាយពាក់ព័ន្ធ នឹងត្រូវកាត់ទុកជាស្វ័យប្រវត្តិដើម្បីទូទាត់។

**២៩**-ទន្ទឹមនឹងនេះ ចំពោះការអនុវត្តការកាត់ទុកជាមុន លើប្រាក់ចំណូលដែលប្រមូលបានពីការផ្តល់សេវាសាធារណៈដែលអនុវត្តដោយក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត សម្រាប់ចំណាយលើប្រាក់រង្វាន់លើកទឹកចិត្តជូនមន្ត្រី និងដើម្បីពង្រឹងយន្តការប្រមូលចំណូល ត្រូវបានចាត់ទុកថាជាថវិកាបុរេប្រទានដែលបានផ្តល់ដោយថវិកាជាតិ។ ថវិកាកាត់ទុកនេះ ត្រូវធ្វើការទូទាត់ និងកត់ត្រាឆ្លុះបញ្ចាំងទាំងចំណូល និងចំណាយនៅក្នុងកិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិរបស់សាមីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដោយត្រូវអនុវត្តតាមនីតិវិធីទូទាត់ថវិកាបុរេប្រទានដូចខាងក្រោម៖

១. *ផ្នែកចំណូល:* ត្រូវធ្វើសលាកប័ត្រចំណូលថវិកាជាតិ ទៅតាមចំនួនទឹកប្រាក់ជាក់ស្តែងដែលត្រូវបានកាត់ទុក ហើយត្រូវអនុវត្តតាមគោលការណ៍ និងនីតិវិធីដូចខាងក្រោម៖

- ចំពោះរដ្ឋបាលកណ្តាល ត្រូវរៀបចំនិងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិមកអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងតារាងស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

- ចំពោះមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំនិងបញ្ជូនសលាកប័ត្រចំណូលថវិកាជាតិ មកមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ដោយភ្ជាប់មកជាមួយនូវរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូល និងតារាងស្តីពីការគណនាប្រាក់រង្វាន់ ព្រមទាំងរបាយការណ៍ស្តីពីការបែងចែកប្រាក់រង្វាន់ដែលបានបើកផ្តល់កន្លងមក។ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តត្រូវចេញលិខិតពិនិត្យបញ្ជាក់លើចំនួនទឹកប្រាក់ដែលបានចុះក្នុងសលាកប័ត្រ។

២. *ផ្នែកចំណាយ:* ត្រូវបោះផ្សាយអាណត្តិបើកប្រាក់(អាណត្តិនិយ័តកម្ម)ទៅតាមចំនួនទឹកប្រាក់ជាក់ស្តែងដែលបានកាត់ទុក និងដូចដែលបានចុះនៅក្នុងសលាកប័ត្រចំណូលថវិកាជាតិ។

**៣០**- ទន្ទឹមនឹងការអនុវត្តចំណាយទៅតាមកម្មវិធីចំណាយ ដំណើរការទូទាត់អាណត្តិបើកប្រាក់ត្រូវផ្តល់អាទិភាពទៅលើចំណាយចាំបាច់ជាប្រចាំមានដូចជាប្រាក់បៀវត្ស ប្រាក់អាហារូបករណ៍ ប្រាក់ឧបត្ថម្ភតាមគោលនយោបាយសង្គមកិច្ច ប្រាក់របបអ្នកជម្ងឺ ការប្រាក់សងបំណុល ទឹក ភ្លើង ទូរស័ព្ទ ភាគទានឱ្យអង្គការអន្តរជាតិនានា និងចំណាយថវិកាបដិភាគរួមចំណែកជាមួយការវិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេស និងបន្ទាប់មកត្រូវផ្អែកលើការទូទាត់ដែលមានចែងក្នុងកិច្ចសន្យាលទ្ធកម្មសាធារណៈ។ ទន្ទឹមនឹងនេះ គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវបង្កើនការសន្សំសំចៃកម្រិតខ្ពស់ ពិសេសលើចំណាយរដ្ឋបាល ដូចជា ប្រេងឥន្ធនៈ សម្ភារៈការិយាល័យ អគ្គិសនី ទឹក ទូរស័ព្ទ ព្រមទាំងចំណាយរដ្ឋបាលផ្សេងៗ ដោយបង្កើនការគ្រប់គ្រងចំណាយឱ្យកាន់តែមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ ព្រមទាំងត្រូវត្រៀមគ្រប់ពេលចំពោះការធ្វើអាទិភាពកម្មឡើងវិញក្នុងករណីចាំបាច់ដោយថាហេតុ សំដៅកាត់បន្ថយចំណាយ ដើម្បីរួមចំណែករក្សាតុល្យភាពថវិកា ស្ថិរភាពថ្លៃ ស្ថិរភាពហិរញ្ញវត្ថុសាធារណៈ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។

៣១- ដើម្បីឱ្យការអនុវត្តចំណាយថវិកាថ្នាក់ជាតិប្រព្រឹត្តទៅបានទាន់ពេលវេលា និងជៀសវាងការចំណាយតិចនៅដើមឆ្នាំ ហើយទៅប្រមូលផ្តុំចំណាយច្រើននៅចុងឆ្នាំ និងម៉្យាងវិញទៀតដើម្បីរក្សាតុល្យភាពថវិកាឱ្យបានរឹងមាំផងនោះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលឱ្យដំណើរការអនុវត្តនីតិវិធីចំណាយ ដូចជាការស្នើសុំធានាចំណាយ និងអនុវត្តវិធីសាស្ត្រលទ្ធកម្មសាធារណៈដូចតទៅ៖

- រដ្ឋមន្ត្រីដែលជាអាណាប័កដើមខ្សែត្រូវប្រញាប់ប្រញាល់ធ្វើប្រកាសស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងការផ្ទេរឥណទានថវិកាជូនគណៈអភិបាលរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដើម្បីឱ្យមន្ទីរជំនាញតាមរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលអាចអនុវត្តនីតិវិធីចំណាយបានទាន់ពេលវេលា។

- ចំពោះចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ត្រូវប្រញាប់ប្រញាល់លើកសំណើសុំគោលការណ៍ធានាចំណាយឱ្យបានទាន់ពេលវេលាមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ឱ្យបាននៅដើមឆ្នាំ និងដើមឆមាស ដើម្បីមានពេលវេលាគ្រប់គ្រាន់សម្រាប់អនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងជៀសវាងបាននូវការអូសបន្លាយការងារលទ្ធកម្ម ដែលធ្វើឱ្យការងារទូទាត់ត្រូវពន្យារដល់ចុងឆ្នាំ នាំឱ្យចំណាយកើនឡើងគំហុកនៅចុងឆ្នាំ។

## ខ.៦ - ការបើកប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ

៣២- ចាប់ពីឆ្នាំ ២០១៤ តទៅ ការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ នឹងអនុវត្តតាមប្រព័ន្ធធនាគារតាមការសម្រេចរបស់រាជរដ្ឋាភិបាល ចំពោះក្រសួង-ស្ថាប័នអាទិភាពចំនួន ៧ ដែលជាសមាជិកគណៈកម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ និងក្រសួង-ស្ថាប័នស្ម័គ្រចិត្តមួយចំនួនទៀត។ ហេតុនេះ ក្រសួង-ស្ថាប័នអាទិភាព ក្រសួង-ស្ថាប័នស្ម័គ្រចិត្ត និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវរៀបចំឯកសារសម្រាប់ការអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារឱ្យបានទាន់ពេលវេលា ដើម្បីធានាប្រសិទ្ធភាពនៃការបើកផ្តល់។ ចំពោះក្រសួង-ស្ថាប័នមួយចំនួនដែលមិនទាន់អាចអនុវត្តការបើកផ្តល់ប្រាក់បៀវត្សតាមប្រព័ន្ធធនាគារបាន ត្រូវពិនិត្យលទ្ធភាពក្នុងការអនុវត្តការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារនេះនៅឆ្នាំបន្តបន្ទាប់ទៀត ដោយសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬទំនាក់ទំនងផ្ទាល់ជាមួយគណៈ-កម្មការចម្រុះទទួលបន្ទុកគម្រោងការបើកផ្តល់បៀវត្សតាមប្រព័ន្ធធនាគារ។

៣៣- ក្រសួងមុខងារសាធារណៈ នឹងបោះពុម្ពឯកសារតារាងបៀវត្សប្រចាំខែនីមួយៗ របស់ក្រសួង-ស្ថាប័ន ព្រមជាមួយការផ្តល់ទិដ្ឋាការ ហើយផ្ញើឱ្យក្រសួង-ស្ថាប័នសាមី យ៉ាងយូរត្រឹមថ្ងៃទី ១០ នៃខែនីមួយៗ។ បន្ទាប់ពីទទួលបានឯកសារតារាងបៀវត្សប្រចាំខែ និងទិដ្ឋាការពីក្រសួងមុខងារសាធា-រណៈ ហើយក្រសួង-ស្ថាប័នសាមី ត្រូវបោះផ្សាយអាណត្តិបើកប្រាក់បៀវត្ស និងចុះហត្ថលេខាក្នុងនាមអាណាប័កដើមខ្សែ ឬ អាណាប័កផ្ទេរសិទ្ធិ តាមរយៈការធ្វើប្រតិភូកម្មសិទ្ធិតាមខ្សែបណ្តោយ ហើយដាក់ឆ្លងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុនៅអមក្រសួង-ស្ថាប័នស្រាប់ ចុះហត្ថលេខាក្នុងនាមអភិបាលហិរញ្ញ-វត្ថុ រួចផ្ញើមកអគ្គនាយកដ្ឋានរតនាគារជាតិ យ៉ាងយូរត្រឹមថ្ងៃទី ១៨ នៃខែនីមួយៗ ដើម្បីអគ្គនាយកដ្ឋាន

រតនាគារជាតិ អាចរៀបចំការបើកផ្ដល់ជូនក្រសួង-ស្ថាប័ននីមួយៗជាបន្តបន្ទាប់ ក្នុងរយៈពេល៥ថ្ងៃ នៃសប្ដាហ៍ទី៤ ទៅតាមលំដាប់អាទិភាពនិងទំហំទឹកប្រាក់ ដែលអាចបើកផ្ដល់បានក្នុងមួយថ្ងៃៗ។

**៣៤**-ចំពោះចំនួនក្របខ័ណ្ឌ និងប្រាក់បៀវត្សរបស់មន្ត្រីរាជការ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី-ខេត្ត ត្រូវតែពិនិត្យអនុវត្តទៅតាមតារាងបៀវត្សដោយប្រព័ន្ធព័ត៌មាន-វិទ្យា ដែលចេញដោយក្រសួងមុខងារសាធារណៈ និងរាល់ក្របខ័ណ្ឌគតិយុត្តិដែលនៅមានជាធរមាន ពិសេសអនុក្រឹត្យ សារាចរណែនាំ និងសេចក្ដីជូនដំណឹងរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងការជ្រើសរើសមន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែត ការត្រួតពិនិត្យឡើងវិញនូវចំនួន និងការគ្រប់គ្រងមន្ត្រីរាជការ និងការកែសម្រួលប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗជាដើម។ ក្នុងករណីមានការផ្ទេរមន្ត្រីរាជការពីក្រសួង-ស្ថាប័នមួយទៅក្រសួង-ស្ថាប័នមួយទៀតនៅក្នុងឆ្នាំ សាមីខ្លួនត្រូវបន្តទទួលបៀវត្សនៅក្រសួង-ស្ថាប័នដើមរហូតដល់ដំណាច់ឆ្នាំ ហើយត្រូវធ្វើការផ្ទេរ និងគ្រោងបៀវត្សនៅក្រសួង-ស្ថាប័នដែលបានផ្ទេរចូលឱ្យទាន់ពេលនៅឆ្នាំបន្ទាប់។ ដើម្បីឱ្យការប្រើប្រាស់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែតមានសង្គតិភាព និងឯកភាពគ្នានៅគ្រប់ក្រសួង-ស្ថាប័នត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់តាមសារាចរលេខ ០០១ សហវ, ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១០ ស្ដីពីការប្រើប្រាស់ និងការផ្ដល់ប្រាក់កម្រៃសម្រាប់មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែត។ ក្រសួង-ស្ថាប័នសាមីត្រូវសុំការយល់ព្រមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាមុន លើការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែត មុននឹងស្នើសុំទិដ្ឋាការពីក្រសួងមុខងារសាធារណៈ។ ទន្ទឹមនឹងនេះ ការអនុវត្តការបើកផ្ដល់ប្រាក់បៀវត្ស ត្រូវអនុវត្តតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដោយក្នុងនោះ៖

-ត្រូវដំឡើងប្រាក់បៀវត្សមូលដ្ឋានប្រចាំខែជូនមន្ត្រីរាជការស៊ីវិលចំនួន៤០ ០០០ រៀល សម្រាប់ក្របខណ្ឌប្រភេទ "ក" និងចំនួន ៨០ ០០០រៀល សម្រាប់ក្របខណ្ឌ ប្រភេទ "ខ" "គ" និង"ឃ"

-ត្រូវផ្ដល់ប្រាក់កម្រៃបន្ថែមចំនួន ៤០ ០០០ រៀល ក្នុងមួយខែលើប្រាក់កម្រៃកិច្ចសន្យាប្រចាំខែសម្រាប់គ្រូបង្រៀនចូលនិវត្តន៍ ដែលត្រូវបានជ្រើសរើសឱ្យបំពេញការងារជាគ្រូជាប់កិច្ចសន្យាចំណេះទូទៅ និងអក្ខរកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា និង

-ត្រូវដំឡើងប្រាក់អាហារដែលជាចំណែកនៃប្រាក់បៀវត្សសម្រាប់យោធិន និងនគរបាលជាតិ ពី ១ ៥០០ រៀល សម្រាប់ម្នាក់ក្នុងមួយថ្ងៃ ទៅ ៤ ២០០ រៀល សម្រាប់ម្នាក់ក្នុងមួយថ្ងៃ ព្រមទាំងដំឡើងប្រាក់ហូបនៅពេលហ្វឹកហាត់ ពីចំនួន ១ ៥០០ រៀល សម្រាប់ម្នាក់ក្នុងមួយថ្ងៃ ទៅចំនួន ៣ ០០០ រៀល សម្រាប់ម្នាក់ក្នុងមួយថ្ងៃដែលត្រូវបើកផ្ដល់ឱ្យទៅអង្គភាព សម្រាប់យោធិន ចំនួន ៥% នៃចំនួនសរុបដែលត្រូវហ្វឹកហាត់សរុបរយៈពេល ៩០ ថ្ងៃ ក្នុងមួយឆ្នាំ។

## ខ.៧ - ការធ្វើចលនាឥណទានថវិកា

**៣៥**- ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ត្រូវប្រើប្រាស់ឥណទានថវិការបស់ខ្លួនទៅតាមប្រកាសស្ដីពីការបែងចែកចំណាយរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានលម្អិតនៅក្នុងសៀវភៅថវិកា។ នៅដើមត្រីមាសទី៣ ក្រោយពីការអនុវត្តត្រីមាសទី២ចប់សព្វគ្រប់មក ក្នុងករណីដែលមានខ្ទង់ចំណាយថវិកាណាមួយមានឥណទានមិនគ្រប់គ្រាន់តែចាំបាច់ត្រូវចំណាយ ត្រូវធ្វើសំណើសុំនិយ័តភាពមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងសម្រេចជាមុនសិនទើបអាចលើកសំណើសុំខ្ទង់ចំណាយ

នោះបាន។ ដើម្បីសម្រួលដល់ការអនុវត្តចំណាយថវិកាកម្មវិធី សិទ្ធិអំណាចត្រូវបានធ្វើប្រតិភូកម្មដល់អាណាប័កដើមខ្សែដែលជាប្រធានក្រសួង-ស្ថាប័ន ក្នុងការធ្វើនិយ័តភាពពីអនុគណនីមួយ ទៅអនុគណនីមួយទៀតនៅក្នុងគណនីតែមួយ។ ការធ្វើនិយ័តភាពនេះ ត្រូវធ្វើឡើងដោយប្រកាសរបស់ក្រសួង-ស្ថាប័នសាមី ដោយមានការចុះហត្ថលេខារបស់រដ្ឋមន្ត្រី ឬប្រធានស្ថាប័នដែលជាអាណាប័កដើមខ្សែ និងត្រូវចម្លងជូនអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីកត់ត្រា តាមដាន និងរៀបចំរបាយការណ៍ចំណាយថវិកាប្រចាំខែ។ បើក្រសួង-ស្ថាប័ន មានសំណូមពរផ្តល់ឥណទានបន្ថែមសម្រាប់ផ្តល់ទៅឱ្យមន្ទីរជំនាញរាជធានី-ខេត្តរបស់ខ្លួន គឺការផ្តល់ឥណទានបន្ថែមនោះ ត្រូវធ្វើឡើងដោយប្រកាសផ្ទេរឥណទានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីឱ្យអភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត (អាណាប័កតាមការប្រទានសិទ្ធិ) ដែលជាខ្សែទទឹង និងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចតាមដានការប្រើប្រាស់ឥណទានថវិកាបន្ថែមទាំងនោះបាន។ ការធ្វើនិយ័តភាពចេញពីថវិកាកម្មវិធីទៅថវិកាមិនមែនកម្មវិធី ឬការធ្វើនិយ័តភាពពីកម្មវិធីមួយទៅកម្មវិធីមួយទៀតត្រូវស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយអាចអនុញ្ញាតឱ្យបានលុះត្រាតែក្រសួង-ស្ថាប័ន មានរបាយការណ៍តាមដានការអនុវត្តកម្មវិធីនីមួយៗយ៉ាងច្បាស់លាស់ ពិសេសប្រធានកម្មវិធី និងប្រធានស្ថាប័ន ត្រូវបញ្ជាក់ថាការធ្វើនិយ័តភាពនេះនឹងមិនប៉ះពាល់ដល់ការសម្រេចបានតាមគោលដៅនៃសូចនាករ និងគោលបំណងរបស់ចង្កោមសកម្មភាព អនុកម្មវិធី កម្មវិធី ក៏ដូចជាទិសដៅគោលនយោបាយរបស់ក្រសួង-ស្ថាប័នឡើយ។

## III. ការត្រួតពិនិត្យ តាមដានការអនុវត្តថវិកា និងការធ្វើរបាយការណ៍

**៣៦**- បណ្តាក្រសួង-ស្ថាប័ននានា សហគ្រាសសាធារណៈ និងអង្គភាពប្រហាក់ប្រហែលត្រូវពង្រឹងតួនាទីរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង/នាយកដ្ឋានសវនកម្មផ្ទៃក្នុងរបស់ខ្លួន ជាមួយគ្នានឹងការពង្រឹងតួនាទីរបស់អគ្គាធិការដ្ឋានរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអគ្គាធិការដ្ឋានក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងការត្រួតពិនិត្យការអនុវត្តថវិកាជាតិ ជាពិសេសការត្រួតពិនិត្យជាក់ស្តែងរាល់ការប្រមូលចំណូល និងការអនុវត្តចំណាយថវិកាជាតិ ដោយវាយតម្លៃការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំតាមបណ្តាក្រសួង-ស្ថាប័ន នានា សហគ្រាសសាធារណៈ និងអង្គភាពប្រហាក់ប្រហែល។

**៣៧**-ដើម្បីបង្កើនគណនេយ្យភាព និងការទទួលខុសត្រូវចំពោះលទ្ធផលនៃចំណាយសាធារណៈ ជាពិសេស ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តថវិកា គ្រប់ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវធ្វើការតាមដានការអនុវត្តថវិការបស់ខ្លួនជាប្រចាំ និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ហើយផ្ញើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(អគ្គនាយកដ្ឋានថវិកា) ឱ្យបានទៀងទាត់ទៅតាមគំរូដែលបានផ្ញើជូន និងទៅតាមកាលបរិច្ឆេទដូចខាងក្រោម៖

- របាយការណ៍ប្រចាំខែ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១០នៃខែបន្ទាប់។
- របាយការណ៍ប្រចាំត្រីមាសត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥នៃខែនៅដើមត្រីមាសបន្ទាប់។
- របាយការណ៍ឆមាសទី១ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមិថុនា។
- របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្ញើមកយ៉ាងយឺតបំផុតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៥។

## IV. វិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

៣៨- ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ត្រូវពង្រឹងតាមវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរៀបចំសៀវភៅណែនាំស្តីពីការរៀបចំបញ្ជីសារពើភ័ណ្ឌ ដើម្បីសម្រួលក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ។

- ក្រសួង ស្ថាប័ន រាជធានី ខេត្ត ត្រូវជំរុញអនុវត្តឱ្យមានប្រសិទ្ធភាព នូវច្បាប់និងលិខិតបទដ្ឋានទាំងឡាយពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ។

- ក្រសួង ស្ថាប័ន រាជធានី ខេត្ត និងនីតិបុគ្គលសាធារណៈ ត្រូវទទួលខុសត្រូវរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល ឆ្នាំ២០១៤ ឱ្យបានតាមពេលកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវបំពេញនាទីជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយទទួលខុសត្រូវខ្ពស់ក្នុងការសម្រេចឱ្យបានតាមការកំណត់ ក្នុងការរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៤ នៅថ្នាក់ក្រោមជាតិ។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះមុខរាជរដ្ឋាភិបាល ក្នុងករណីមិនអាចសម្រេចបាននូវការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋតាមពេលវេលាកំណត់ និងពុំបានចុះបញ្ជីអស់គ្រប់ចំនួននូវទ្រព្យសម្បត្តិចូលក្នុងបញ្ជីសារពើភ័ណ្ឌ។

## V. វិធានការរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា

៣៩- នៅពេលដែលពិនិត្យឃើញថាស្ថានភាពនៃការអនុវត្តថវិកានឹងមិនអាចសម្រេចបានទៅតាមការគ្រោងទុក ដើម្បីរក្សាតុល្យភាព និងប្រសិទ្ធភាពថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នត្រូវមានវិធានការដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងសហការជាមួយក្រសួងផែនការ និងធនាគារជាតិនៃកម្ពុជា ដើម្បីបន្តបង្កើនការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំនូវស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ច ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់ជាអវិជ្ជមានពីខាងក្រៅ និងរក្សាឱ្យបាននូវស្ថិរភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចនៅកម្ពុជា។

- ក្រសួង-ស្ថាប័ន និង មន្ទីរជំនាញរាជធានី-ខេត្តទាំងអស់ត្រូវបង្កើនការយកចិត្តទុកដាក់ក្នុងការតាមដានការអនុវត្តថវិកា និងសកម្មភាពការងាររបស់ខ្លួនជាប្រចាំ និងអនុវត្តប្រកបដោយភាពទន់ភ្លន់ទៅតាមសភាពការណ៍ហិរញ្ញវត្ថុនិងសេដ្ឋកិច្ច និងត្រៀមវិធានការដោះស្រាយប្រកបដោយប្រសិទ្ធភាពដោយជៀសវាងប៉ះពាល់ដល់សកម្មភាពអាទិភាពខ្ពស់ ក្នុងករណីមានការតម្រឹមចំណាយជាយថាហេតុ។

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យ លើការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ដើម្បីជាមូលដ្ឋានក្នុងការធ្វើថវិកាកែតម្រូវក្នុងករណីចាំបាច់។

## VI. ទណ្ឌកម្មនិងការទទួលខុសត្រូវចំពោះមន្ត្រីសាធារណៈ

៤០- មន្ត្រីសាធារណៈគ្រប់ប្រភេទ និងគ្រប់ឋានៈកំពុងប្រតិបត្តិការរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវការអនុវត្តអភិបាលកិច្ចល្អឱ្យមានប្រសិទ្ធភាពខ្ពស់តាមវិធាន-ការច្បាប់ និងលិខិតបទដ្ឋានជាធរមានដូចខាងក្រោម៖

-ចាត់វិធានការរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈណាដែលបានប្រព្រឹត្តនូវកំហុសឆ្គងក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យទទួលទោសតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងទទួលតាមកម្រិតទោសទណ្ឌនៃក្រមនីតិវិធីរដ្ឋប្បវេណី និង ក្រមនីតិព្រហ្មទណ្ឌ

-គ្រប់មន្ត្រីសាធារណៈ ត្រូវហ៊ានទទួលខុសត្រូវនូវកំហុសឆ្គងដែលបានប្រព្រឹត្ត និងកំពុងអនុវត្តប្រតិបត្តិការលើការគ្រប់គ្រងចំណូល ចំណាយថវិការដ្ឋទៅតាមបទដ្ឋានគតិយុត្តិនៃវិន័យហិរញ្ញវត្ថុសាធារណៈ សារាចរ ប្រកាស អនុក្រឹត្យ ដែលបានណែនាំដោយរាជរដ្ឋាភិបាល

-ចាត់វិធានការតាមវិន័យរដ្ឋបាល និងតុលាការចំពោះមន្ត្រីសាធារណៈដែលបានធ្វើឱ្យបាត់បង់ប្រាក់កាស ឬខូចខាតទ្រព្យសម្បត្តិសាធារណៈ ទោះតម្លៃនៃការបាត់បង់ ឬខូចខាតរួមទាំងការប្រាក់លើតម្លៃបាត់បង់ ឬខូចខាតបានក្លាយជាបំណុលសាធារណៈក្តី មន្ត្រីសាធារណៈនោះត្រូវសង និងត្រូវបង់ជាប្រាក់កាសសាធារណៈចូលថវិការដ្ឋវិញ។

## VII. សេចក្តីសន្និដ្ឋាន

**៤១**-ថវិកាឆ្នាំ២០១៤ នេះ ជាឧបករណ៍គោលនយោបាយដ៏មានសារៈសំខាន់បំផុតសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ ដែលបានស្តែងឡើងតាមរយៈការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៥ ពិសេសតាមរយៈការជំរុញអនុវត្តនូវ "គោលដៅជាយុទ្ធសាស្ត្រ ៤" និង "វិស័យអាទិភាព ៤" នៃ "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" ។ ទន្ទឹមនឹងនេះ ថវិកាឆ្នាំ២០១៤ ក៏បានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់និងមុតស្រួចរបស់រាជរដ្ឋាភិបាល ក្នុងការបន្តរក្សាស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម បន្តពង្រឹងនិងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ បន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងធានាបាននូវភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពខ្ពស់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការទ្រទ្រង់កំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាក្នុងការអនុវត្តកម្មវិធីអភិវឌ្ឍន៍និងកំណែទម្រង់លើគ្រប់វិស័យឱ្យកាន់តែស៊ីជម្រៅ និងឱ្យមានលទ្ធផលជាក់ស្តែងដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃដំណើរផ្លាស់ប្តូរជារចនាសម្ព័ន្ធនៃសេដ្ឋកិច្ចសង្គមកម្ពុជាផង និងឆន្ទៈរបស់ប្រជាពលរដ្ឋផង ព្រមទាំងដើម្បីពង្រីកនិងពង្រឹងមូលដ្ឋានសម្រាប់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសម្រាប់រយៈពេលវែងផងដែរ។

**៤២**-ក្នុងន័យនេះ ថវិកាឆ្នាំ២០១៤ ត្រូវបានប្រសិទ្ធនាមថា "ជាថវិកានៃការចាប់ផ្តើមដំណើរការផ្លាស់ប្តូររបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាពនិងចិរភាព ការគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ចនិងការបែងចែកផលកំណើនសេដ្ឋកិច្ចភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងការគិតគូរដល់ការអភិវឌ្ឍរយៈពេលវែងក្នុងបរិការណ៍សមាហរណកម្មស៊ីជម្រៅក្នុងតំបន់ ការវិវឌ្ឍនៃសកលភាវូបនីយកម្ម ក៏ដូចជាការពង្រឹងសមត្ថភាពគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យស្របទៅនឹងដំណាក់កាលថ្មីរបស់កម្ពុជា"។

**៤៣**-ក្នុងនាមរាជរដ្ឋាភិបាល ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមអំពាវនាវដល់តួអង្គពាក់ព័ន្ធទាំងអស់ផ្តល់ការគាំទ្រនិងចូលរួមអនុវត្តដោយសកម្មដោយឈរលើគោលការណ៍សាមគ្គីភាព ឯកភាពជាតិ និងតម្កល់ផលប្រយោជន៍របស់ជាតិនិងប្រជាជនជាធំ ជាពិសេសត្រូវរួមគ្នាជាធ្លុងមួយជុំវិញរាជរដ្ឋាភិបាល ក្នុងការប្តេជ្ញាចិត្តសម្រេចឱ្យបាននូវគោលដៅ និងវិធានការទាំងឡាយដែលបានលើកឡើងខាងលើប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ តាមរយៈការប្រកាន់ខ្ជាប់នូវអភិក្រមការងារថ្មី៤

យ៉ាងគឺ«**ផ្ទុះកញ្ជាក់ ងូតទឹក ដុសក្អែល និងព្យាបាល**» ដូចដែលប្រមុខរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញក្នុង «**កិច្ចប្រជុំគណៈរដ្ឋមន្ត្រីលើកដំបូងកាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣**»។

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**<u>កន្លែងទទួល</u>**

- អគ្គលេខាធិការដ្ឋានក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាបជាព័ត៌មាន"

- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់រាជធានី ខេត្ត

"ដើម្បីអនុវត្ត"

-រាជកិច្ច

"ដើម្បីផ្សព្វផ្សាយ"

- ឯកសារ-កាលប្បវត្តិ